ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 33

# ប្រាក់ចំណេញក្នុងមួយភាគហ៊ុន

## Earnings per Share

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ពន្ធ័ទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ពន្ធ័នៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ចី តាយី**

## គោលបំណង

១ គោលបំណងនៃស្តង់ដានេះ គឺដើម្បីប្រាប់ពីគោលការណ៍សំរាប់ការកំណត់ និងការដាក់បង្ហាញប្រាក់ចំណេញក្នុងមួយភាគហ៊ុន ធ្វើដូច្នេះគឺដើម្បីធ្វើឲ្យប្រសើរឡើងនូវការប្រៀបធៀបលទ្ធផល រវាងអង្គភាពខុសៗគ្នា នៅក្នុងការិយបរិច្ឆេទរាយការណ៍ដូចគ្នា និងរវាងការិយបរិច្ឆេទរាយការណ៍ខុសៗគ្នាសំរាប់អង្គភាពដូចគ្នា។ ទោះបីជាទិន្នន័យប្រាក់ចំណេញក្នុងមួយភាគហ៊ុនមានការកម្រិតដោយសារតែគោលនយោបាយគណនេយ្យខុសៗគ្នា ដែលអាចត្រូវបានប្រើដើម្បីកំណត់ពី "ប្រាក់ចំណេញ" ភាគយក ដែលបានកំណត់ដូចៗគ្នានឹងធ្វើឲ្យ ប្រសើឡើងនូវការរាយការណ៍ហិរញ្ញវត្ថុ។ ចំណុចសំខាន់នៃស្តង់ដានេះគឺស្ថិតនៅលើភាគយកនៃការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុន។

## វិសាលភាព

**២ ស្តង់ដានេះត្រូវអនុវត្តចំពោះ**

**(ក) របាយការណ៍ហិរញ្ញវត្ថុមួយៗ និងដាច់ដោយឡែករបស់អង្គភាពមួយៈ**

**(១) ដែលភាគហ៊ុនធម្មតាឬភាគហ៊ុនធម្មតារបស់អង្គភាពដែលមានសក្តានុពលត្រូវបានជួញដូរនៅក្នុងទីផ្សារសាធារណៈ (ទីផ្សារភាគហ៊ុនក្រៅប្រទេស ឬទីផ្សារ**

តាមបញ្ជរ រួមបញ្ចូលទាំងទីផ្សារក្នុងប្រទេស និងទីផ្សារក្នុងតំបន់) ឬ

(២) ដែលដាក់របាយការណ៍ហិរញ្ញវត្ថុ ឬស្ថិតក្នុងដំណាក់នៃការដាក់របាយការណ៍ហិរញ្ញវត្ថុ របស់ខ្លួនជាមួយគណៈកម្មការមូលបត្រ ឬស្ថាប័នច្បាប់ផ្សេងទៀតសំរាប់គោលបំណង បោះផ្សាយភាគហ៊ុនធម្មតានៅក្នុងទីផ្សារសាធារណៈ និង

(ខ) របាយការណ៍ហិរញ្ញវត្ថុរួមរបស់បណ្តុំក្រុមហ៊ុនជាមួយនឹងក្រុមហ៊ុនមេៈ

(១) ដែលភាគហ៊ុនធម្មតាឬភាគហ៊ុនធម្មតាដែលបានសក្តានុពលត្រូវបានគេជួញដូរនៅក្នុងទីផ្សារសាធារណៈ (ទីផ្សារភាគហ៊ុនក្នុងស្រុកឬក្រៅប្រទេស ឬទីផ្សារតាមបញ្ជររួមទាំងទីផ្សារក្នុងស្រុកនិងក្នុងតំបន់ផង) ឬ

(២) ដែលដាក់របាយការណ៍ ឬស្ថិតនៅក្នុងដំណើរការដាក់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាមួយ គណៈកម្មការមូលបត្រឬស្ថាប័នច្បាប់ផ្សេងទៀតសំរាប់គោលបំណងបោះផ្សាយ ភាគហ៊ុនធម្មតា នៅក្នុងទីផ្សារសាធារណៈ។

៣ អង្គភាពមួយដែលលាតត្រដាងពីប្រាក់ចំណេញក្នុង១ភាគហ៊ុនត្រូវគណនា និងលាតត្រដាងពីប្រាក់ចំណេញ ក្នុងភាគហ៊ុនដោយអនុលោមតាមស្តង់ដារនេះ។

៤ នៅពេលដែលអង្គភាពមួយបង្ហាញទាំងរបាយការណ៍ហិរញ្ញវត្ថុរួម និង

របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ដែលបានរៀបចំ ដោយអនុលោមតាម ស.គ.អ.ក ២៧ *របាយការណ៍ហិរញ្ញវត្ថុ និងដាច់ដោយឡែក* ការលាតត្រដាងដែលបានតម្រូវដោយស្តង់ដានេះចាំបាច់ត្រូវបានដាក់បង្ហាញតែតាមមូលដ្ឋានព័ត៌មានហិរញ្ញវត្ថុ។ អង្គភាពមួយដែលជ្រើសរើស ដើម្បីលាតត្រដាងប្រាក់ចំណេញក្នុង១ភាគហ៊ុនដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ខ្លួនត្រូវដាក់បង្ហាញព័ត៌មានប្រាក់ចំណេញក្នុង១ភាគ-ហ៊ុនតែនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ។ អង្គភាពមួយមិនត្រូវដាក់បង្ហាញព័ត៌មានប្រាក់ចំណេញក្នុង១ភាគហ៊ុនបែបនេះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមទេ។

៤ក ប្រសិនបើ អង្គភាពមួយដាក់បង្ហាញសមាសធាតុនៃរបាយការណ៍ការចំណេញ ឬខាត នៅក្នុងរបាយការណ៍លទ្ធផលដាច់ដោយឡែកដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ៨១ នៃ ស.គ.អ.ក ១ *ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* (ដូចបានកែប្រែនៅក្នុងឆ្នាំ ២០០៧) អង្គភាពដាក់បង្ហាញប្រាក់ចំណេញក្នុងមួយភាគហ៊ុន តែនៅក្នុងរបាយការណ៍ដាច់ ដោយឡែកនោះតែប៉ុណ្ណោះ។

## និយមន័យ

៥ វាក្យស័ព្ទខាងក្រោមត្រូវបានប្រើនៅក្នុងស្តង់ដានេះជាមួយនឹងអត្ថន័យដូចមានបញ្ជាក់ខាងក្រោមៈ

*ការការពារការបន្ទាប* គឺជាការកើនឡើងនៅក្នុងប្រាក់ចំណេញក្នុងមួយភាគហ៊ុន ឬការកាត់បន្ថយនៅក្នុងការខាតក្នុងមួយភាគហ៊ុន ដែលកើត

ចេញពីការសន្មតថាឧបករណ៍ដែលអាចបំលែងបានត្រូវបានគេបំលែងជាសិទ្ធិពិសេស ឬជាដីកាត្រូវបានគេអនុវត្ត ឬជាភាគហ៊ុនធម្មតាត្រូវបានចេញផ្សាយនៅលើការពេញចិត្តនៃលក្ខខណ្ឌជាក់លាក់។

*កិច្ចព្រមព្រៀងភាគហ៊ុនយថាហេតុ* គឺជាកិច្ចព្រមព្រៀងមួយ ដើម្បីបោះផ្សាយភាគហ៊ុនដែលអាស្រ័យលើ ការពេញចិត្តនៃលក្ខខណ្ឌជាក់លាក់។

*ភាគហ៊ុនធម្មតាដែលអាចបោះផ្សាយបានជាយថាហេតុ* គឺជាភាគហ៊ុនធម្មតាដែលអាចបោះផ្សាយដើម្បី ទទួលបានសាច់ប្រាក់ ឬមិនមានសាច់ប្រាក់ ឬក៏តម្លៃតបស្នងផ្សេងទៀតនៅលើការពេញចិត្តនៃលក្ខខណ្ឌជាក់លាក់នៅក្នុងកិច្ចព្រមព្រៀងភាគហ៊ុនយថាហេតុ។

*ការបន្ទាប* គឺជាការកាត់បន្ថយនៅក្នុងប្រាក់ចំណេញក្នុង១ភាគហ៊ុន ឬការបង្កើននៅក្នុងការខាតក្នុងមួយភាគហ៊ុនដែលកើតចេញពីការសន្មតដែលឧបករណ៍អាចបំលែងបានត្រូវបានបំលែង ជាសិទ្ធិពិសេស ឬដីកាត្រូវបានអនុវត្ត ឬជាភាគហ៊ុនធម្មតាត្រូវបានបោះផ្សាយនៅលើការពេញចិត្តនៃលក្ខខណ្ឌជាក់លាក់។

*សិទ្ធិពិសេស ដីកា និងភាពសមមូល* គឺជាឧបករណ៍ហិរញ្ញវត្ថុដែលផ្តល់ឲ្យអ្នកកាន់កាប់ឧបករណ៍នូវសិទ្ធិ ដើម្បីទិញភាគហ៊ុនធម្មតា។

*ភាគហ៊ុនធម្មតា* គឺជាឧបករណ៍មូលធនដែលគាំទ្រចំពោះថ្នាក់ទាំងអស់ផ្សេងទៀតនៃឧបករណ៍ហិរញ្ញវត្ថុ។

*ភាគហ៊ុនធម្មតាដែលមានសក្តានុពល* គឺជាឧបករណ៍ហិរញ្ញវត្ថុ ឬជាកិច្ចសន្យាផ្សេងទៀត ដែលអាចផ្តល់សិទ្ធិឲ្យអ្នកកាន់ឧបករណ៍ ឬកិច្ចសន្យាចំពោះភាគហ៊ុនធម្មតា។

*សិទ្ធិលក់ពិសេស* **លើភាគហ៊ុនធម្មតា គឺជាកិច្ចសន្យាដែលផ្តល់សិទ្ធិឱ្យអ្នកកាន់ភាគហ៊ុនដើម្បីលក់ភាគហ៊ុន ធម្មតាតាមតំលៃជាក់លាក់នៃការិយបរិច្ឆេទមួយ។**

៦ ភាគហ៊ុនធម្មតាចូលរួមនៅក្នុងផលចំណេញ សម្រាប់ការិយបរិច្ឆេទតែបន្ទាប់ពីប្រភេទផ្សេងទៀត នៃភាគហ៊ុន ដូចជាភាគហ៊ុនអាទិភាព បានចូលរួមប៉ុណ្ណោះ។ អង្គភាពមួយអាចមានថ្នាក់នៃភាគហ៊ុនធម្មតាច្រើនជាងមួយ ភាគហ៊ុនធម្មតានៃថ្នាក់ដូចគ្នាមានសិទ្ធិដូចគ្នាដើម្បីទទួលបានភាគលាភ។

៧ ឧទាហរណ៍នៃភាគហ៊ុនធម្មតាគឺៈ

(ក) បំណុលហិរញ្ញវត្ថុ ឬឧបករណ៍មូលធន រួមបញ្ចូលទាំងភាគហ៊ុនអាទិភាព ដែលអាចបំលែងបានទៅជាភាគហ៊ុនធម្មតា

(ខ) សិទ្ធិពិសេស និងដីកា

(គ) ភាគហ៊ុន ដែលអាចត្រូវបានចេញផ្សាយ លើការពេញចិត្តនៃលក្ខខណ្ឌដែលកើតចេញពីការរៀបចំកិច្ចព្រមព្រៀង ដូចជា ការទិញអាជីវកម្ម ឬទ្រព្យសកម្មផ្សេងទៀត។

៨ វាក្យស័ព្ទដែលបានកំណត់នៅក្នុង ស.គ.អ.ក ៣២ *ឧបករណ៍ហិរញ្ញវត្ថុៈ* ត្រូវបានប្រើនៅក្នុងស្តង់ដានេះជាមួយនឹងអត្ថន័យដូចបានបញ្ជាក់នៅក្នុងកថាខណ្ឌ ១១ នៃ ស.គ.អ.ក ៣២ លើកលែងតែបានធ្វើកំណត់សំគាល់។ ស.គ.អ.ក៣២ កំណត់ពីឧបករណ៍ហិរញ្ញវត្ថុ ទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ ឧបករណ៍មូលធន និងតម្លៃសមស្រប និងផ្តល់ការណែនាំលើការអនុវត្តនិយមន័យទាំងនោះ។

ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន

៩ អង្គភាពមួយត្រូវគណនាទឹកប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន សម្រាប់ចំណេញ ឬខាត ដែលបែងចែក ទៅឱ្យអ្នកកាន់មូលធនធម្មតារបស់ក្រុមហ៊ុនមេ និងចំណេញ ឬខាតពីកិច្ចប្រតិបត្តិការកំពុងបន្តដែលបែងចែកទៅឱ្យអ្នកកាន់មូលធនទាំងនោះ ប្រសិនបើបានដាក់បង្ហាញ។

១០ ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋានត្រូវបានគណនាដោយការបែងចែក ចំណេញ ឬខាត ដែលបែងចែក ទៅឱ្យអ្នកកាន់មូលធនធម្មតារបស់អង្គភាពមេ (ភាគយក) ដោយចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលកំពុងដំណើរការ (ភាគបែង) ក្នុងកំឡុងការិយបរិច្ឆេទ។

១១ គោលបំណងនៃព័ត៌មានចំណេញ ក្នុងមួយភាគហ៊ុនជាមូលដ្ឋាន គឺដើម្បីផ្តល់នូវការវាស់វែងពីការប្រាក់នៃភាគហ៊ុនធម្មតានីមួយៗរបស់អង្គភាពមេនៅក្នុងលទ្ធផលរបស់អង្គភាពលើការិយបរិច្ឆេទរាយការណ៍។

ប្រាក់ចំណេញ

១២ សម្រាប់គោលបំណងនៃការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន ទឹកប្រាក់ដែលបែងចែក ទៅឱ្យអ្នកកាន់មូលធនធម្មតារបស់អង្គភាពមេដែលទាក់ទិននឹង:

(ក) ប្រាក់ចំណេញឬខាតពីកិច្ចប្រតិបត្តិការបន្តដែលបែងចែកទៅឱ្យអង្គភាពមេ និង

(ខ) ប្រាក់ចំណេញដែលបែងចែកទៅឱ្យអង្គភាពមេ

**ត្រូវតែជាទឹកប្រាក់នៅក្នុង (ក) និង (ខ) ដែលបានកែសម្រួលសម្រាប់ទឹកប្រាក់ បន្ទាប់ពីបង់ពន្ធរួចនៃភាគលាភអាទិភាពភាពខុសគ្នា ដែលកើតឡើងពីការទូទាត់នៃភាគហ៊ុនអាទិភាព ឥទ្ធិពលស្រដៀងគ្នាផ្សេងទៀតនៃភាគហ៊ុន អាទិភាពដែលបានចាត់ថ្នាក់ជាមូលធន។**

១៣ រាល់ធាតុទាំងអស់នៃចំណូល និងចំណាយ ដែលបែងចែកទៅឱ្យអ្នកកាន់មូលធនធម្មតា នៃអង្គភាពមេ ដែលត្រូវបានទទួលស្គាល់ នៅក្នុងការិយបរិច្ឆេទមួយ រួមបញ្ចូលទាំងចំណាយពន្ធ និងភាគលាភលើភាគហ៊ុនអាទិភាព ដែលបានចាត់ថ្នាក់ជាបំណុលត្រូវបានរួមបញ្ចូលនៅក្នុងការកំណត់ប្រាក់ចំណេញ ឬខាតសម្រាប់ការិយបរិច្ឆេទដែលបែងចែកទៅឱ្យអ្នកកាន់ មូលធនធម្មតារបស់អង្គភាពមេ (សូមមើល ស.គ.អ.ក ១)។

១៤ ទឹកប្រាក់បន្ទាប់ពីបង់ពន្ធរួចនៃភាគលាភភាគហ៊ុនអាទិភាព ដែលត្រូវបានកាត់ចេញពីរបាយការណ៍ចំណេញ ឬខាតគឺ:

(ក) ទឹកប្រាក់ បន្ទាប់ពីបង់ពន្ធរួច នៃភាគលាភភាគហ៊ុនអាទិភាពណាមួយលើភាគហ៊ុនអាទិភាពមិនបូកបន្ត ដែលបានប្រកាសចែកនៅក្នុងការិយបរិច្ឆេទ និង

(ខ) ទឹកប្រាក់បន្ទាប់ពីបង់ពន្ធរួចនៃភាគលាភភាគហ៊ុនអាទិភាពសម្រាប់ ភាគហ៊ុនអាទិភាពបូកបន្តដែលបានតម្រូវឱ្យមានសម្រាប់ការិយបរិច្ឆេទ ថាតើភាគលាភត្រូវបានគេប្រកាសចែកឬអត់។ ទឹកប្រាក់ នៃភាគលាភភាគហ៊ុនអាទិភាពសម្រាប់ការិយបរិច្ឆេទមិនរួមបញ្ចូល ទឹកប្រាក់នៃភាគលាភភាគហ៊ុនអាទិភាពណាមួយសម្រាប់ភាគហ៊ុន អាទិភាពបូកបន្តដែលបានបង់ ឬបានប្រកាស

ចែកក្នុងកំឡុង ការិយបរិច្ឆេទ បច្ចុប្បន្នទាក់ទិននឹងការិយបរិច្ឆេទមុន។

១៥ ភាគហ៊ុនអាទិភាពដែលផ្តល់នូវភាគលាភដំបូងទាបដើម្បីតបស្នងឲ្យអង្គ-ភាពមួយដើម្បីលក់ភាគហ៊ុនអទិភាពតាមតម្លៃអប្បហារ ឬភាគលាភលើតម្លៃ ទីផ្សារនៅក្នុងការិយបរិច្ឆេទក្រោយដើម្បីតបស្នងឲ្យអ្នកវិនិយោគសំរាប់ការទិញភាគហ៊ុនអាទិភាព តាមតម្លៃលើសពេលខ្ពីត្រូវបានគេសំដៅដល់ការ កើនឡើងអត្រាភាគហ៊ុនអាទិភាព។ អប្បហារឬតម្លៃលើសពីការបោះផ្សាយ ដំបូងលើការបង្កើនអត្រាភាគហ៊ុនអាទិភាពត្រូវបានធ្វើរំលស់ធៀបនឹងប្រាក់ ចំណេញរក្សាទុកដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនិងត្រូវបានចាត់ ទុកជាភាគលាភភាគហ៊ុនអាទិភាពសម្រាប់គោលបំណងនៃការគណនា ចំណេញក្នុងមួយភាគហ៊ុន។

១៦ ភាគហ៊ុនអាទិភាពអាចត្រូវបានទិញមកវិញក្រោមការផ្តល់របស់អ្នកឲ្យរបស់អ្នកស្នើសុំរបស់អង្គភាពទៅអ្នកកាន់មូលធន។ចំណែកលើសតម្លៃសមស្របនៃតម្លៃតបស្នងដែលបានបង់ទៅឲ្យម្ចាស់ភាគហ៊ុនអាទិភាពលើតម្លៃយោងនៃភាគហ៊ុនអាទិភាព តំណាងឲ្យចំណូល ចំពោះអ្នកកាន់ភាគហ៊ុនអាទិភាពនិងជាបន្ទុកចំពោះប្រាក់ចំណេញរក្សាទុកសម្រាប់មូលធន។ទឹកប្រាក់នេះត្រូវបានកាត់បន្ថយនៅក្នុងការគណនាប្រាក់ចំណេញ ឬខាត ដែលបែងចែកទៅ អ្នកកាន់មូលធនធម្មតារបស់អង្គភាពមេ។

១៧ ការបំលែងមុនពេលនៃភាគលាភអាទិភាព ដែលអាចបំលែងបាន អាចត្រូវបានណែនាំ ដោយអង្គភាពមួយតាមរយៈការផ្លាស់ប្តូរល្អ ចំពោះលក្ខខណ្ឌបំលែងដំបូង ឬការទូទាត់តម្លៃតបស្នងបន្ថែម។ ចំណែកលើសនៃតម្លៃសមស្របនៃភាគហ៊ុនធម្មតា ឬតម្លៃតបស្នងផ្សេងទៀត ដែលបានបង់លើតម្លៃ

សមស្រេបនៃភាគហ៊ុនធម្មតា ដែលអាចបោះផ្សាយបាន ក្រោមលក្ខខណ្ឌបំលែងដំបូងគឺជាចំណូលចំពោះភាគហ៊ុនអាទិភាព និងត្រូវបានកាត់បន្ថយនៅក្នុងការគណនាប្រាក់ចំណេញឬខាតដែលបែងចែកទៅឱ្យអ្នកកាន់មូលធនធម្មតារបស់អង្គភាពមេ។

១៨ ចំណែកលើសនៃតម្លៃយោង នៃភាគហ៊ុនអាទិភាព លើតម្លៃសមស្របនៃតម្លៃតបស្នងដែលបានបង់ដើម្បី សងពួកគេត្រូវបានបូកបន្ថែម នៅក្នុងការគណនាប្រាក់ចំណេញឬខាត ដែលបែងចែកទៅឱ្យអ្នកកាន់មូលធនធម្មតានៃអង្គភាពមេ។

**ភាគហ៊ុន**

**១៩ សម្រាប់គោលបំណងនៃការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន ចំនួនភាគហ៊ុនធម្មតាត្រូវតែជា ចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលកំពុងមានក្នុងកំឡុងការិយបរិច្ឆេទ។**

២០ ការប្រើប្រាស់ចំនួនមធ្យមនៃភាគហ៊ុនធម្មតាកំពុងមាន ក្នុងកំឡុងការិយបរិច្ឆេទឆ្លុះបញ្ចាំងពីភវនីយភាព ដែលទឹកប្រាក់នៃដើមទុនរបស់ម្ចាស់ភាគហ៊ុនបានប្រែប្រួលក្នុងកំឡុងការិយបរិច្ឆេទជាលទ្ធផលនៃចំនួនភាគហ៊ុនធំជាងឬតូចជាង ដែលកំពុងមាននៅពេលណាក៏បាន។ ចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលកំពុងមានក្នុង កំឡុងការិយបរិច្ឆេទគឺជាចំនួននៃភាគហ៊ុនធម្មតានៅដើមការិយបរិច្ឆេទ ដែលត្រូវបានកែសម្រួលដោយចំនួន នៃភាគហ៊ុនធម្មតា ដែលបានទិញត្រឡប់វិញ ឬត្រូវបានបោះផ្សាយ ក្នុងកំឡុងការិយបរិច្ឆេទដោយគុណនឹងកត្តាមធ្យមពេលវេលា។កត្តាមធ្យមពេលវេលា

គឺជាចំនួនថ្ងៃដែលភាគហ៊ុនកំពុងកើតមាន ជាសមាមាត្រនៃចំនួនថ្ងៃសរុបនៅក្នុងការិយបរិច្ឆេទ ការប៉ាន់ស្មានដ៏សមហេតុសមផលនៃមធ្យមភាគ គឺមានភាគគ្រប់គ្រាន់នៅក្នុងកាលៈទេសៈជាច្រើន។

២១ ភាគហ៊ុនជាទូទៅ ត្រូវបានរួមបញ្ចូល នៅក្នុងចំនួនភាគហ៊ុនមធ្យមពីកាលបរិច្ឆេទ ដែលតម្លៃតបស្នងត្រូវទទួល (ដែលជាទូទៅគឺជាថ្ងៃបោះផ្សាយ) ឧទាហរណ៍:

(ក) ភាគហ៊ុនធម្មតា ដែលបានចេញផ្សាយនៅក្នុងការដោះដូរសម្រាប់សាច់ប្រាក់ ត្រូវបានរួមបញ្ចូលនៅពេលសាច់ប្រាក់អាចទទួលបាន

(ខ) ភាគហ៊ុនធម្មតា ដែលបានបោះផ្សាយតាមការវិនិយោគបន្ត ដោយស្ម័គ្រចិត្តនៃភាគលាភ ឬភាគហ៊ុនអាទិភាពត្រូវបានរួមបញ្ចូលនៅពេលដែលភាគលាភត្រូវបានគេវិនិយោគបន្ត

(គ) ភាគហ៊ុនធម្មតា ដែលបានបោះផ្សាយ ជាលទ្ធផលនៃការបំលែងនៃឧបករណ៍បំណុល ទៅជាភាគហ៊ុនធម្មតាត្រូវបានរួមបញ្ចូលចាប់ពីកាលបរិច្ឆេទដែលការប្រាក់ឈប់បង្គរតទៅទៀត

(ឃ) ភាគហ៊ុនធម្មតាដែលបានបោះផ្សាយដើម្បីការប្រាក់ ឬប្រាក់ដើមលើឧបករណ៍ហិរញ្ញវត្ថុត្រូវបានរួម បញ្ចូលចាប់ពីកាលបរិច្ឆេទ ដែលការប្រាក់ឈប់បង្គរតទៅទៀត

(ង) ភាគហ៊ុនធម្មតា ដែលបានបោះផ្សាយ នៅក្នុងការដោះដូរសម្រាប់ការទូទាត់បំណុលរបស់អង្គភាព ត្រូវបានរួមបញ្ចូលចាប់ពីកាលបរិច្ឆេទទូទាត់

(ច) ភាគហ៊ុនធម្មតា ដែលបានបោះផ្សាយជាតម្លៃតបស្នង សម្រាប់ការទិញទ្រព្យសកម្មក្រៅពីសាច់ប្រាក់ត្រូវបានរួមបញ្ចូលនៅត្រឹមកាលបរិច្ឆេទ ដែលការទិញត្រូវបានទទួលស្គាល់ និង

(ឆ) ភាគហ៊ុនធម្មតា ដែលបានបោះផ្សាយ សម្រាប់ការផ្តល់សេវាទៅឱ្យអង្គភាពត្រូវបានរួមបញ្ចូលនៅពេលសេវាត្រូវបានផ្តល់។

ពេលវេលានៃការបញ្ចូលភាគហ៊ុនធម្មតា ត្រូវបានកំណត់ដោយលក្ខខណ្ឌដោយភ្ជាប់ទៅនឹងការបោះផ្សាយរបស់គេ។ តម្លៃតបស្នងដែលនៅជំពាក់ត្រូវបានផ្តល់ទៅឱ្យភាពសំខាន់នៃកិច្ចសន្យាណាដែលជាប់ពាក់ព័ន្ធជាមួយនឹងការបោះផ្សាយ។

២២ ភាគហ៊ុនធម្មតាដែលបានបោះផ្សាយធ្វើជាផ្នែកមួយនៃតម្លៃតបស្នង ដែលបានផ្ទេរនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នាត្រូវបានរួមបញ្ចូល នៅក្នុងចំនួនមធ្យមនៃភាគហ៊ុន ចាប់ពីកាលបរិច្ឆេទទិញ។ នេះដោយសារតែអ្នកទិញបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផលលម្អិតនូវចំណេញ និងខាតរបស់អ្នកលក់ចាប់ពីកាលបរិច្ឆេទ នោះ។

២៣ ភាគហ៊ុនធម្មតាដែលនឹងត្រូវបានបោះផ្សាយនៅពេលការបំលែងឧបករណ៍ដែលអាចបំលែងបានចាំបាច់ ត្រូវបានបញ្ចូលនៅក្នុងការគណនាចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋានចាប់ពីកាលបរិច្ឆេទ ដែលកិច្ចសន្យាបានចូលជាធរមាន។

២៤ ភាគហ៊ុនដែលអាចបោះផ្សាយបានជាយថាហេតុ ត្រូវបានចាត់ទុកជាភាគហ៊ុនកំពុងដំណើរការ ហើយត្រូវបានគេបញ្ចូលនៅក្នុងការគណនាចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋានតែចាប់ពីកាលបរិច្ឆេទ ដែលលក្ខខណ្ឌចាំបាច់

ទាំងអស់ត្រូវបានបំពេញចិត្ត(ពោលគឺព្រឹត្តិការណ៍បានកើតឡើង)។ភាគហ៊ុន ដែលអាចបោះផ្សាយបានតែប៉ុណ្ណោះ បន្ទាប់ពីការកន្លងផុតទៅ នៃពេលវេលាមិនមែនជាភាគហ៊ុនដែលអាចបោះផ្សាយបានជាយថាហេតុ ដោយសារតែការកន្លងផុតទៅ នៃពេលវេលាមានភាពប្រាកដប្រជា។ ភាគហ៊ុនធម្មតាដែលកំពុងដំណើរការដែលអាចបង្វិលមកវិញជាយថាហេតុ (ពោលគឺជាកម្មវត្ថុនៃការហៅត្រឡប់មកវិញ) មិនត្រូវបានចាត់ទុកថាកំពុងដំណើរការទេ និងត្រូវបានដកចេញពីការគណនាចំណោញក្នុងមួយភាគហ៊ុនរហូតដល់កាលបរិច្ឆេទដែលភាគហ៊ុនឈប់ជាកម្មវត្ថុនៃការហៅត្រឡប់មកវិញ។

២៥ [លុបចោល]

**២៦ ចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលកំពុងដំណើរការក្នុងកំឡុងការិយបរិច្ឆេទ និងសម្រាប់គ្រប់ការិយបរិច្ឆេទ ទាំងអស់ដែលបានដាក់បង្ហាញ ត្រូវបានគេកែសម្រួល សម្រាប់ព្រឹត្តិការណ៍ក្រៅពីការបំលែងភាគហ៊ុនធម្មតាដែលមានសក្តានុពល ដែលបានធ្វើឲ្យប្រែប្រួលចំនួនភាគហ៊ុនកំពុងដំណើរការ ដោយ គ្មានការប្រែប្រួល ធនធានស្របគ្នា។**

២៧ ភាគហ៊ុនធម្មតាអាចត្រូវបានបោះផ្សាយ ឬចំនួននៃភាគហ៊ុនធម្មតា ដែលកំពុងដំណើរការអាចត្រូវបានកាត់បន្ថយ ដោយគ្មានការប្រែប្រួលធនធានស្របគ្នាទេ។

ឧទាហរណ៍រួមមាន:

(ក) ការធ្វើមូលធនកម្ម ឬការបោះផ្សាយប្រាក់បន្ថែម (ជួនកាលត្រូវបានគេហៅថាភាគលាភជាភាគហ៊ុន)

(ខ) សមាសធាតុប្រាក់បន្ថែម ដែលមាននៅក្នុងការបោះផ្សាយផ្សេង

ទៀត ឧទាហរណ៍ សមាសធាតុប្រាក់បន្ថែម នៅក្នុងការផ្តល់សិទ្ធិ ទៅឲ្យម្ចាស់ភាគហ៊ុនដែលមានស្រាប់ដើម្បីទិញភាគហ៊ុនមុនគេ

(គ) ការបំបែកសន្លឹកហ៊ុន និង

(ឃ) ការបំបែកសន្លឹកហ៊ុនត្រឡប់វិញ (ការបង្រួមភាគហ៊ុន)។

២៨ នៅក្នុងការធ្វើមូលធនកម្ម ឬការបោះផ្សាយសម្រាប់ប្រាក់បន្ថែម ឬការបំបែក សន្លឹកហ៊ុនភាគហ៊ុនធម្មតា ត្រូវបានចេញផ្សាយទៅឲ្យម្ចាស់ភាគហ៊ុនដែលមានស្រាប់មិនមានតម្លៃតបស្នងបន្ថែម។ ដូច្នេះចំនួនភាគហ៊ុនធម្មតាដែលកំពុងដំណើរការ គឺត្រូវបានបង្កើន ដោយគ្មានការកើនឡើងធនធានទេ ។ ចំនួនភាគហ៊ុនធម្មតា ដែលកំពុងដំណើរការមុនព្រឹត្តិការណ៍ត្រូវបានកែសម្រួលសម្រាប់ការប្រែប្រួល តាមសមាមាត្រក្នុងចំនួនភាគហ៊ុនដែលកំពុងដំណើរការ ប្រសិនបើព្រឹត្តិកាណ៍បានកើតឡើងនៅដើមការិយបរិច្ឆេទ ដំបូងបង្អស់ ដែលបានដាក់បង្ហាញ។ ឧទាហរណ៍ការបោះផ្សាយសំរាប់ ប្រាក់បន្ថែមចំនួនពីរសំរាប់មួយចំនួនភាគហ៊ុនធម្មតាដែលកំពុងដំណើរការ មុនពេល ដែលការបោះផ្សាយត្រូវបានគុណនឹង ៣ដើម្បីទទួលបានចំនួន ភាគហ៊ុនធម្មតាសរុប ឬនឹង២ដើម្បីទទួលបានចំនួនភាគហ៊ុនធម្មតាបន្ថែម។

២៩ ការបង្រួមភាគហ៊ុនធម្មតា ជាទូទៅកាត់បន្ថយចំនួនភាគហ៊ុនធម្មតា ដែលកំពុងដំណើរការដោយពុំមានការកាត់បន្ថយធនធានស្របគ្នា។ ប៉ុន្តែ នៅពេលដែលឥទ្ធិពលរួមគឺជាការទិញមកវិញនូវភាគហ៊ុនតាមតម្លៃ សមស្របការកាត់បន្ថយចំនួនភាគហ៊ុនធម្មតាដែលកំពុងដំណើរការគឺជាលទ្ធផលនៃការកាត់បន្ថយធនធានស្របគ្នា។ ឧទាហរណ៍ គឺការបង្រួមភាគហ៊ុនដែល

បញ្ចូលជាមួយភាគលាភពិសេស។ ចំនួនភាគហ៊ុនមធ្យម ដែលកំពុងដំណើរការសម្រាប់ការិយបរិច្ឆេទដែលប្រតិបត្តិការបញ្ចូលរួចកើតមានឡើងត្រូវបានកែសម្រួល សម្រាប់ការកាត់បន្ថយចំនួនភាគហ៊ុនធម្មតា ចាប់ពីកាល-បរិច្ឆេទ ដែលភាគលាភពិសេសត្រូវបានទទួលស្គាល់។

ប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប

៣០ **អង្គភាពមួយត្រូវគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាបសម្រាប់ប្រាក់ចំណេញ ឬខាត ដែលបែងចែកទៅឲ្យអ្នកកាន់មូលធនធម្មតារបស់អង្គភាពមេ និងប្រាក់ចំណេញឬខាតពីកិច្ចប្រតិបត្តិការបន្តដែលបែងចែកទៅឲ្យ អ្នកកាន់មូលធនទាំងនោះ ប្រសិនបើបានដាក់បង្ហាញ ។**

៣១ **សម្រាប់គោលបំណងនៃការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប អង្គភាពមួយត្រូវកែសម្រួលចំណេញ ឬខាត ដែលបែងចែកទៅឲ្យអ្នកកាន់មូលធនធម្មតារបស់អង្គភាពមេ ហើយចំនួនភាគហ៊ុនមធ្យម ដែលកំពុងដំណើរការសម្រាប់ឥទ្ធិពលនៃភាគហ៊ុនធម្មតាបន្ទាបដែលមានសក្តានុពល។**

៣២ គោលបំណងនៃប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាបមានសង្គតិភាព ជាមួយនឹងប្រាក់ចំណេញក្នុងមួយ ភាគហ៊ុនជាមូលដ្ឋាន ដើម្បីផ្តល់ការវាស់វែងពីការប្រាក់ នៃភាគហ៊ុនធម្មតានីមួយៗ នៅក្នុងលទ្ធផលរបស់អង្គភាពខណៈពេលដែលដឹងថាឥទ្ធិពលចំពោះភាគហ៊ុនធម្មតា ដែលមានសក្តានុ-ពលបន្ទាកំពុងដំណើរការក្នុងកំឡុងការិយបរិច្ឆេទ។

ជាលទ្ធផលៈ

(ក) ចំណេញឬខាតដែលបែងចែកទៅឲ្យអ្នកកាន់មូលធនធម្មតា របស់

អង្គភាពមេត្រូវបានបង្កើនដោយភាគលាភក្រោយការបង់ពន្ធនិង ការប្រាក់ ដែលបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ដែលទាក់ទិននឹងភាគហ៊ុនធម្មតាបន្សាបដែលមានសក្តានុពល ហើយត្រូវបានកែសម្រួលសម្រាប់ការផ្លាស់ប្តូរ ផ្សេងទៀតនៅក្នុងចំណូល ឬ ចំណាយដែលនឹងកើតចេញពី ការបំលែងភាគហ៊ុនធម្មតា ដែល មានសក្តានុពលបន្សាប និង

(ខ) ចំនួនភាគហ៊ុនធម្មតាមធ្យមដែលកំពុងដំណើរការ ត្រូវបានបង្កើនដោយចំនួនមធ្យមនៃភាគហ៊ុនធម្មតាបន្ថែម ដែលកំពុងដំណើរការដោយសន្មតថាមានការបំលែងភាគហ៊ុនធម្មតាដែលមានសក្តានុ-ពលបន្សាបទាំងអស់។

ប្រាក់ចំណេញ

៣៣ **សម្រាប់គោលបំណងនៃការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាបអង្គភាពមួយត្រូវធ្វើការសម្រួល ប្រាក់ចំណេញ ឬខាត ដែលបែងចែកទៅឲ្យអ្នកកាន់មូលធនធម្មតារបស់អង្គភាពមេ ដូចដែលបានគណនា ដោយអនុលោមតាមកថាខណ្ឌ ១២ ដោយឥទ្ធិពលក្រោយការបង់ពន្ធនៃៈ**

**(ក) ភាគលាភណាមួយ ឬធាតុផ្សេងទៀតដែលទាក់ទិននឹងភាគហ៊ុនធម្មតាបន្សាបដែលមានសក្តានុពល ដែលត្រូវបានកាត់បន្ថយដើម្បីទទួលបានចំណេញឬខាតដែលបែងចែកទៅឲ្យអ្នកកាន់មូលធនធម្មតារបស់អង្គភាពមេដូចដែលបានគណនា ដោយអនុលោមតាម កថាខណ្ឌ ១២។**

(ខ) **ការប្រាក់ណាមួយដែលបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ដែលទាក់ទិននឹងភាគហ៊ុនធម្មតា ដែលមានសក្តានុពលបន្សាប**

(គ) **ការប្រែប្រួលចំណូលឬចំណាយផ្សេងទៀតដែលកើតឡើងពីការបំលែងភាគហ៊ុនធម្មតាដែលមាន សក្តានុពលបន្សាប។**

៣៤ បន្ទាប់ពីភាគហ៊ុនធម្មតា ដែលមានសក្តានុពលត្រូវបានបំលែងទៅជាភាគហ៊ុនធម្មតា ធាតុដែលបានកំណត់ នៅក្នុងកថាខណ្ឌ ៣៣ (ក) -(គ) ឈប់កើតឡើងតទៅទៀត ឬភាគហ៊ុនធម្មតាថ្មីៗត្រូវបានផ្តល់សិទ្ធិ ដើម្បីចូលរួមនៅក្នុងចំណេញឬខាតដែលបែងចែកទៅឲ្យអ្នកកាន់មូលធនធម្មតារបស់អង្គភាពមេ ។ ដូច្នេះ ចំណេញ ឬខាត ដែលបែងចែកទៅឲ្យអ្នកកាន់ភាគហ៊ុនធម្មតារបស់អង្គភាពមេដែលបានគណនាដោយអនុលោមតាមកថាខណ្ឌ ១២ ត្រូវបានកែសម្រួលសម្រាប់ធាតុដែលបានកំណត់អត្តសញ្ញាណនៅក្នុងកថាខណ្ឌ ៣៣(ក)-(គ) និង ពន្ធពាក់ព័ន្ធ។ ចំណាយដែលជាប់ ទាក់ទង នឹងភាគហ៊ុនធម្មតាដែលមានសក្តានុពលរួមបញ្ចូលទាំងចំណាយប្រតិបត្តិការ និងអប្បហារដែលបានធ្វើគណនេយ្យកម្មដោយអនុលោមតាមវិធីសាស្រ្ត ការប្រាក់ប្រសិទ្ធភាព (សូមមើលកថាខណ្ឌ ៩ នៃ ស.គ.អ.ក ៣៩ *ឧបករណ៍ហិរញ្ញវត្ថុ ការទទួលស្គាល់ និងការវាស់វែង* ដូចបានកែប្រែនៅ ក្នុងឆ្នាំ២០០៣)។

៣៥ ការបំលែងភាគហ៊ុនធម្មតាដែលមានសក្តានុពលអាចនាំដល់ការប្រែប្រួលចំណូលឬចំណាយ។ ឧទាហរណ៍ ការថយចុះនៃចំណាយការប្រាក់ ដែលទាក់ទិននឹងភាគហ៊ុនធម្មតាដែលមានសក្តានុពល និងការកើនឡើងនៅក្នុងប្រាក់ចំណេញ ឬការថយចុះនៅក្នុងការខាតអាចនាំដល់ការកើនឡើងនៅ

ក្នុងចំណាយដែលទាក់ទិន នឹងផែនការបែងចែកប្រាក់ចំណេញ មិនមែនតាមការសម្រេចចិត្ត សម្រាប់និយោជិក ។ សំរាប់គោលបំណងនៃការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប ប្រាក់ចំណេញ ឬខាតដែលបែងចែកទៅឱ្យអ្នកកាន់មូលធន ធម្មតារបស់អង្គភាពមេ ត្រូវបានកែសម្រួលសម្រាប់ ការប្រែប្រួលចំណូល ឬចំណាយ។

**ភាគហ៊ុន**

៣៦ **សម្រាប់គោលបំណងនៃការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប ចំនួនភាគហ៊ុនធម្មតាត្រូវតែជាចំនួនភាគហ៊ុនធម្មតា ដែលបានគណនាដោយអនុលោមតាមកថាខណ្ឌ ១៩ និង ២៦ បូកនឹងចំនួនភាគហ៊ុនធម្មតាមធ្យមដែលនឹងត្រូវបានបោះផ្សាយនៅពេលធ្វើការបំលែងភាគហ៊ុនធម្មតាដែលមានសក្តានុពលបន្ទាបទៅជាភាគហ៊ុនធម្មតា។ ភាគហ៊ុនធម្មតាដែលបានសក្តានុពលបន្ទាបត្រូវបានចាត់ទុកថា ត្រូវបានគេបំលែងទៅជាភាគហ៊ុនធម្មតានៅដើមការិយបរិច្ឆេទ ឬនៅកាលបរិច្ឆេទនៃការបោះផ្សាយ ភាគហ៊ុនធម្មតាដែលមានសក្តានុពល ប្រសិនបើនៅពេលក្រោយ។**

៣៧ ភាគហ៊ុនធម្មតាបន្ទាបដែលមានសក្តានុពលត្រូវបានកំណត់ដោយឯករាជ្យសម្រាប់ការិយបរិច្ឆេទនីមួយដែលបានដាក់បង្ហាញ។ ចំនួននៃភាគហ៊ុនធម្មតា បន្ទាបដែលមានសក្តានុពលបានរួមបញ្ចូល នៅក្នុងការិយបរិច្ឆេទត្រឹមថ្ងៃ បិទបញ្ជីគឺមិនមែនជាមធ្យមនៃភាគហ៊ុនធម្មតាបន្ទាបដែលមានសក្តានុពលដែលបានបញ្ចូលនៅក្នុង ការគណនាបណ្តោះអាសន្ន។

៣៨ ភាគហ៊ុនធម្មតាដែលមានសក្តានុពលត្រូវបានធ្វើជាមធ្យម សម្រាប់ការិយ-

បរិច្ឆេទដែលពួកគេកំពុងដំណើរការ។ភាគហ៊ុនធម្មតាដែលមានសក្តានុពលដែលត្រូវបានលុបចោល ឬត្រូវបានអនុញ្ញាតដើម្បីឲ្យអស់សុពលភាពក្នុងកំឡុងការិយបរិច្ឆេទដែលត្រូវបានបញ្ចូលនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាបតែ សម្រាប់ចំណែកនៃការិយបរិច្ឆេទក្នុងកំឡុងពេលដែលភាគហ៊ុនកំពុងដំណើរការ ។ ភាគហ៊ុនធម្មតា ដែលមានសក្តានុពលដែលត្រូវបានបំលែងទៅជាភាគហ៊ុនធម្មតាក្នុងកំឡុងការិយ-បរិច្ឆេទត្រូវបានបញ្ចូលនៅក្នុងការ គណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប ចាប់ពីដើមការិយបរិច្ឆេទមកត្រឹមកាលបរិច្ឆេទបំលែង ចាប់ពីកាលបរិច្ឆេទបំលែងភាគហ៊ុនធម្មតាដែលកើតមានត្រូវបានបញ្ចូលនៅក្នុងទាំងប្រាក់ចំណេញក្នុងមួយភាគ ហ៊ុនជាមូលដ្ឋាននិងបន្ទាប។

៣៩ ចំនួននៃភាគហ៊ុនធម្មតា ដែលនឹងត្រូវបានបោះផ្សាយលើការបំលែងភាគហ៊ុនធម្មតាបន្ទាបដែលមានសក្តានុពលត្រូវបានកំណត់ពីលក្ខខណ្ឌនៃភាគហ៊ុនធម្មតាដែលមានសក្តានុពល។ នៅពេលដែលមានមូលដ្ឋានបំលែងលើសពីមួយកើតឡើងការគណនាសន្មតពីអត្រាបំលែង ដែលមានគុណសម្បត្តិច្រើន ឬតម្លៃអនុវត្ត ពីចំណុចឈរជើងនៃអ្នកកាន់ភាគហ៊ុនធម្មតាដែលមានសក្តានុពល។

៤០ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន ឬសមាគត អាចបោះផ្សាយទៅឲ្យភាគីក្រៅពីក្រុមហ៊ុនមេ ភាគីរួមទុន ឬអ្នកវិនិយោគនូវភាគហ៊ុនធម្មតា ដែលមានសក្តានុពល ដែលអាចបំលែងទៅជាភាគហ៊ុនធម្មតា របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន ឬសមាគត ឬភាគហ៊ុនធម្មតានៃក្រុមហ៊ុនមេ ភាគីរួមទុន ឬអ្នកវិនិយោគ (អង្គភាពរាយការណ៍)។ ប្រសិនបើភាគហ៊ុន

ធម្មតាដែលមានសក្តានុពលទាំងនេះរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន ឬសមាគត មានឥទ្ធិពលបន្សាបលើប្រាក់ចំណេញក្នុងមួយភាគជាមូលដ្ឋានរបស់អង្គភាពរាយការណ៍ ភាគហ៊ុនទាំងនោះត្រូវបានបញ្ចូលទៅក្នុងការគណនាចំណេញក្នុងមួយភាគហ៊ុនបន្សាប។

**ភាគហ៊ុនធម្មតាបន្សាបដែលមានសក្តានុពល**

៤១ **ភាគហ៊ុនធម្មតាដែលមានសក្តានុពល ត្រូវបានទទួលស្គាល់ជាបន្សាបនៅពេលដែល និងតែនៅពេលដែល ការបំលែងរបស់គេទៅជាភាគហ៊ុនធម្មតាអាចបន្ថយប្រាក់ចំណេញក្នុងភាគហ៊ុន ឬបង្កើនខាតក្នុងមួយភាគហ៊ុនពីកិច្ចប្រតិបត្តិការកំពុងបន្ត។**

៤២ អង្គភាពមួយប្រើប្រាក់ចំណេញ ឬខាត ពីកិច្ចប្រតិបត្តិការកំពុង បន្តដែលបែងចែកទៅឲ្យក្រុមហ៊ុនមេ ជាលេខគ្រប់គ្រង ដើម្បីបង្កើតជាភាគហ៊ុនធម្មតាដែលមានសក្តានុពលគឺបន្សាបឬការការពារបន្សាប។ ប្រាក់ចំណេញ ឬខាតពីកិច្ចប្រតិបត្តិការបន្តដែលបែងចែកទៅឲ្យអង្គភាពមេត្រូវបានកែសម្រួលដោយអនុលោមតាមកថាខណ្ឌ ១២ និងដកចេញនូវធាតុដែលទាក់ទិន នឹងកិច្ចប្រតិបត្តិការមិនបន្ត។

៤៣ ភាគហ៊ុនធម្មតា ដែលមានសក្តានុពលគឺជាការការពារការបន្សាបនៅពេលដែលការបំលែងទៅជាភាគហ៊ុនធម្មតានឹងបង្កើនចំណេញក្នុងមួយភាគហ៊ុន ឬនឹងបន្ថយការខាត ក្នុងមួយភាគហ៊ុនពីកិច្ចប្រតិបត្តិការបន្ត ។ ការគណនាប្រាក់ចំណេញបន្សាបក្នុងមួយភាគហ៊ុនមិនសន្មតពីការបំលែង ការអនុវត្ត ឬការបោះផ្សាយនៃភាគហ៊ុនធម្មតា ដែលមានសក្តានុពលដែលមាន

ឥទ្ធិពលការការពារបន្សាបលើចំណេញក្នុងមួយភាគហ៊ុន។

៤៤ នៅក្នុងការកំណត់ថាតើភាគហ៊ុនធម្មតាដែលមានសក្តានុពលជាបន្សាប ឬជាការការពារការបន្សាប ទេការបោះផ្សាយនីមួយៗ ឬចំនួនភាគហ៊ុនធម្មតាដែលមានសក្តានុពល ត្រូវបានពិចារណាដាច់ដោយឡែក ជាជាងសរុបបញ្ចូលគ្នា។ លេខរៀងដែលភាគហ៊ុនធម្មតាដែលមានសក្តានុពលត្រូវបានពិចារណាអាចប៉ះពាល់ ថាតើពួកគេជាបន្សាប។ ដូច្នេះ ដើម្បីធ្វើឱ្យអប្បបរមានូវការបន្សាបនៃប្រាក់ចំណេញក្នុងមួយភាគហ៊ុន ការបោះផ្សាយនីមួយៗ ឬចំនួននៃភាគហ៊ុនធម្មតា ដែលមានសក្តានុពល ត្រូវបានគេពិចារណាតាមលេខរៀង ចាប់ពីការបន្សាបច្រើនបំផុត ទៅការបន្សាបតិចបំផុត ពោលគឺ ភាគហ៊ុនធម្មតាបន្សាប ដែលមានសក្តានុពល ដែលមានប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ថែមទាបជាងគេបំផុតត្រូវបានបញ្ចូលនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាបមុនពេលភាគហ៊ុនដែល មានប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ថែមខ្ពស់ជាង។ សិទ្ធិពិសេស និងដីកា ជាទូទៅ ត្រូវបានបញ្ចូលលើកដំបូង ពីព្រោះពួកគេមិនធ្វើឱ្យប៉ះពាល់ដល់ភាគយកនៃការគណនាទេ។

### *សិទ្ធិពិសេស ដីកា និង ភាពសមមូលរបស់ពួកគេ*

៤៥ **សម្រាប់គោលបំណងនៃការគណនាប្រាក់ចំណេញក្នុងមួយភាគបន្សាប អង្គភាពមួយត្រូវសន្មតថាមានការអនុវត្តសិទ្ធិពិសេសបន្សាប និងដីការបស់អង្គភាព។ ចំណូលសន្មតរួចពីឧបករណ៍ទាំងនេះត្រូវបានចាត់ទុកថាបានទទួលពីការបោះផ្សាយភាគហ៊ុនធម្មតាតាមតម្លៃទីផ្សារមធ្យមនៃភាគហ៊ុន**

**ធម្មតាក្នុងកំឡុងការិយបរិច្ឆេទ។ ភាពខុសគ្នារវាងចំនួនភាគហ៊ុនធម្មតាដែលបានបោះផ្សាយ និងចំនួនភាគហ៊ុនធម្មតាដែលនឹងត្រូវបានបោះផ្សាយតាមតម្លៃទីផ្សារមធ្យមនៃភាគហ៊ុនធម្មតាក្នុងកំឡុងការិយបរិច្ឆេទត្រូវបានចាត់ទុកជាការបោះផ្សាយនៃភាគហ៊ុនធម្មតាដោយមិនមានតម្លៃតបស្នង។**

៤៦ សិទ្ធិពិសេស និងដីកា ដែលបន្សាបនៅពេលដែលពួកគេនាំឲ្យមានការបោះផ្សាយភាគហ៊ុនធម្មតាសម្រាប់ តម្លៃទាបជាងទីផ្សារនៃភាគហ៊ុនធម្មតាក្នុងកំឡុងការិយបរិច្ឆេទ។ ទឹកប្រាក់នៃការបន្សាបគឺជាតម្លៃទីផ្សារមធ្យមនៃភាគហ៊ុនធម្មតាក្នុងកំឡុងការិយបរិច្ឆេទដកចេញ នូវតម្លៃបោះផ្សាយ។ ដូច្នេះ ដើម្បីគណនាប្រាក់ ចំណេញក្នុងមួយភាគហ៊ុនបន្សាប ភាគហ៊ុនធម្មតាដែលមានសក្តានុពល ត្រូវបានចាត់ទុកថាមានសង្គតិភាព នៃលក្ខ-ខណ្ឌទាំងពីរខាងក្រោមៈ

(ក) កិច្ចសន្យា ដើម្បីបោះផ្សាយចំនួនភាគហ៊ុនធម្មតាជាក់លាក់តាមតម្លៃទីផ្សារមធ្យមរបស់គេ ក្នុងកំឡុងការិយបរិច្ឆេទ។ ភាគហ៊ុនធម្មតាបែបនេះត្រូវបានសន្មតថាត្រូវបានកំណត់តម្លៃយ៉ាងត្រឹមត្រូវ និងមិនមែនជាបន្សាប និងមិនមែនជាការការពារការបន្សាប។ ពួកគេ ត្រូវបានទាត់ចោលនៅក្នុងការគណនា នៃប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាប។

(ខ) កិច្ចសន្យាដើម្បីបោះផ្សាយភាគហ៊ុនធម្មតាដែលនៅសល់ ដោយមិនមានតម្លៃតបស្នង។ ភាគហ៊ុនធម្មតាបែបនេះ មិនបង្កើតចំណូល និងមិនមានឥទ្ធិពលលើប្រាក់ចំណេញ ឬខាត ដែលបែង

ចែកទៅឲ្យភាគហ៊ុនធម្មតាដែលកំពុងដំណើរការ។ ដូច្នេះភាគហ៊ុនបែបនេះជាបន្ទាប និងត្រូវបានបូកបន្ថែមទៅនឹងចំនួនភាគហ៊ុនធម្មតាដែលកំពុងដំណើរការនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប។

៤៧ សិទ្ធិពិសេស និងដីកា មានឥទ្ធិពលបន្ទាបតែនៅពេល ដែលតម្លៃទីផ្សារមធ្យមនៃភាគហ៊ុនធម្មតាក្នុងកំឡុង ការិយបរិច្ឆេទលើសតម្លៃអនុវត្តនៃសិទ្ធិពិសេស ឬដីកា (ពោលគឺពួកគេជាលុយ)។ ប្រាក់ចំណេញក្នុងមួយភាគហ៊ុនដែលបានរាយការណ៍គ្រាមុន មិនត្រូវបានកែសម្រួលប្រតិសកម្មទេ ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួល តម្លៃភាគហ៊ុនធម្មតា។

៤៧ក សម្រាប់សិទ្ធិពិសេសទិញភាគហ៊ុន និងការរៀបចំទូទាត់ ផ្អែកលើភាគហ៊ុនផ្សេងទៀតដែលត្រូវប្រើ ស.រ.ហ.អ.ក ២ *ការទូទាត់ផ្អែកលើភាគហ៊ុន* តម្លៃបោះផ្សាយដែលយោងទៅក្នុងកថាខណ្ឌ ៤៦ និងតម្លៃអនុវត្ត ដែលយោងទៅក្នុងកថាខណ្ឌ ៤៧ ត្រូវរួមបញ្ចូលតំលៃសមស្របនៃទំនិញ ឬសេវាដែលត្រូវផ្គត់ផ្គង់ទៅឲ្យអង្គភាពនាពេលអនាគតក្រោមសិទ្ធិពិសេសទិញភាគហ៊ុន ឬការរៀបចំការទូទាត់ផ្អែកលើភាគហ៊ុនផ្សេងទៀត។

៤៨ សិទ្ធិពិសេសទិញភាគហ៊ុនរបស់និយោជិកជាមួយនឹងលក្ខខណ្ឌថេរ ឬអាចកំណត់បាន និងភាគហ៊ុនធម្មតាមិនផ្ទេរត្រូវបានចាត់ទុកជាសិទ្ធិពិសេសនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប ទោះបីជាយ៉ាងណាក៏ដោយពួកគេអាចមានលក្ខណៈជាយថាហេតុលើការផ្ទេរ ។ ពួកគេត្រូវបានចាត់ទុកជាសិទ្ធិពិសេសទិញ ភាគហ៊ុនរបស់និយោជិកកំពុងដំណើរការនៅកាលបរិច្ឆេទផ្តល់។ សិទ្ធិពិសេសទិញភាគហ៊ុនរបស់និយោជិក ដែល

ផ្អែកលើលទ្ធផលត្រូវបានចាត់ទុកជាភាគហ៊ុនដែលអាចបោះផ្សាយជាយថាហេតុដោយសារតែការបោះផ្សាយរបស់គេមានលក្ខណៈយថាហេតុ លើការបំពេញលក្ខខណ្ឌជាក់លាក់បន្ថែមទៅការកន្លងផុតនៃពេលវេលា។

*ឧបករណ៍ដែលអាចបំលែងបាន ។*

៤៩ ឥទ្ធិពលបន្សាបនៃឧបករណ៍ដែលអាចបំលែងត្រូវបានឆ្លុះបញ្ចាំង នៅក្នុងប្រាក់ចំណេញក្នុងមួយភាគហ៊ុន បន្សាបដោយអនុលោមតាម កថាខណ្ឌ ៣៣ និង ៣៦។

៥០ ភាគហ៊ុនអាទិភាពដែលអាចបំលែងបាន គឺការការពារការបន្សាបនៅពេលណាដែលទឹកប្រាក់នៃភាគលាភលើភាគហ៊ុនបែបនេះ ដែលបានប្រកាសចែកនៅក្នុង ឬបានបូកបន្តសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្នក្នុងមួយភាគហ៊ុនធម្មតា ដែលអាចទទួលបានលើការបំលែង ដែលលើសប្រាក់ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន។ ស្រដៀងគ្នានេះដែរ បំណុលអាចបំលែង គឺការការពារការបន្សានៅពេលណាក៏ដោយដែលភាគកម្មរបស់គេ (បន្ទាប់ពីបង់ពន្ធរួច និងការផ្លាស់ប្តូរផ្សេងទៀតនៅក្នុងចំណូល ឬចំណាយ) ក្នុងមួយភាគហ៊ុនធម្មតាដែលអាចទទួលបានលើការបំលែងលើសប្រាក់ចំណេញក្នុងមួយភាគហ៊ុនធម្មតា។

៥១ ការហៅត្រឡប់មកវិញ ឬការបំលែង បានណែនាំរួចនៃភាគហ៊ុនអាទិភាពដែលអាចបំលែងបាន អាចប៉ះពាល់តែចំណែកមួយនៃភាគហ៊ុនអាទិភាពដែលអាចបំលែងបានកំពុងដំណើរការពីគ្រាមុន។ នៅក្នុងករណីបែបនេះ តម្លៃតបស្នងដែលលើសដែលបានយោងទៅក្នុងកថាខណ្ឌ ១៧ ត្រូវបានបែងចែកទៅឱ្យភាគហ៊ុនទាំងនោះ ដែលត្រូវបានហៅមកវិញ ឬត្រូវបាន

បំលែងសំរាប់គោលបំណងនៃការកំណត់ថាតើភាគហ៊ុនអាទិភាព ដែលកំពុង តែដំណើរការនៅសេសសល់គឺបន្ទាប។ ភាគហ៊ុនដែលបានហៅមកវិញ ឬបានបំលែងត្រូវគិតដាច់ដោយឡែកពីភាគហ៊ុនដែលមិនត្រូវបានហៅមក វិញ ឬត្រូវបានបំលែង។

*ភាគហ៊ុនដែលអាចបោះផ្សាយបានដោយថាហេតុ*

៥២ ដូចគ្នាទៅនឹងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុន ជាមូលដ្ឋានដែរ ភាគហ៊ុនធម្មតាដែលអាចបោះផ្សាយ បានជាយថាហេតុត្រូវបានចាត់ទុកថាកំពុងដំណើរការនិងត្រូវបានរួមបញ្ចូលទៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប ប្រសិនបើលក្ខខណ្ឌត្រូវបានបំពេញ (ពោលគឺព្រឹត្តិការណ៍បានកើតឡើង)។ ភាគហ៊ុនដែលអាចបោះផ្សាយជាយថាហេតុត្រូវបានបញ្ចូលចាប់តាំងពីដើមការិយបរិច្ឆេទ (ឬ ពីកាលបរិច្ឆេទ នៃកិច្ចព្រមព្រៀងភាគហ៊ុនយថាហេតុ ប្រសិនជានៅពេលក្រោយ)។ ប្រសិនបើលក្ខខណ្ឌមិនត្រូវបានបំពេញចិត្តទេនោះ ចំនួននៃភាគហ៊ុនដែលអាចបោះផ្សាយជាយថាហេតុដែលបានរួមបញ្ចូលនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាត្រូវបានផ្អែកលើចំនួនភាគហ៊ុនដែលអាចបោះផ្សាយបាន ប្រសិនបើនៅចុងការិយបរិច្ឆេទ គឺជាចុងការិយបរិច្ឆេទយថាហេតុនោះ។ ការបង្ហាញឡើងវិញមិនត្រូវបានអនុញ្ញាតិទេ ប្រសិនបើលក្ខខណ្ឌទាំងឡាយមិនត្រូវបានបំពេញនៅពេលដែលការិយបរិច្ឆេទយថាហេតុអស់សុពលភាព។

៥៣ ប្រសិនបើការសម្រេចបាន ឬការថែទាំ នៃទឹកប្រាក់ជាក់លាក់ នៃប្រាក់ចំណេញ សម្រាប់ការិយបរិច្ឆេទគឺជាលក្ខខណ្ឌ សម្រាប់ការបោះផ្សាយជាយថាហេតុ និងប្រសិនបើ ទឹកប្រាក់នោះត្រូវបានគេធ្វើឲ្យសម្រេចនៅចុងការិយបរិច្ឆេទរាយការណ៍ ប៉ុន្តែត្រូវតែរក្សាលើសពីការិយបរិច្ឆេទរាយ-ការណ៍ សម្រាប់ការិយបរិច្ឆេទបន្ថែម បន្ទាប់មកចំនួនភាគហ៊ុនធម្មតាបន្ថែមត្រូវបាន ចាត់ទុកថាកំពុងដំណើរការ ប្រសិនបើឥទ្ធិពលគឺមានលក្ខណៈបន្សាបនៅពេលធ្វើការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាប ។ នៅក្នុងករណីនោះ ការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាប គឺផ្អែកលើចំនួនភាគហ៊ុនធម្មតាដែលអាចត្រូវបោះផ្សាយ ប្រសិនបើទឹកប្រាក់ នៃប្រាក់ចំណេញនៅចុងការិយបរិច្ឆេទរាយការណ៍ គឺជាទឹកប្រាក់នៃប្រាក់ចំណេញនៅចុងការិយបរិច្ឆេទយថាហេតុ ។ ពីព្រោះតែប្រាក់ចំណេញអាចប្រែប្រួល នៅក្នុងការិយបរិច្ឆេទអនាគត ការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋានមិនបញ្ចូលភាគហ៊ុនធម្មតាដែលអាចបោះផ្សាយជាយថាហេតុរហូតដល់ចុងការិយបរិច្ឆេទយថាហេតុពីព្រោះលក្ខខណ្ឌចាំបាច់មិន ទាំងអស់ទេដែលត្រូវបានបំពេញចិត្ត ។

៥៤ ចំនួនភាគហ៊ុនធម្មតាដែលអាចបោះផ្សាយជាយថាហេតុអាចអាស្រ័យលើតម្លៃទីផ្សារអនាគត នៃភាគហ៊ុនធម្មតា។ នៅក្នុងករណីនោះ ប្រសិនបើឥទ្ធិពលគឺជាការបន្សាប ការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាបត្រូវផ្អែកលើចំនួនភាគហ៊ុនធម្មតាដែលអាចត្រូវបានបោះផ្សាយប្រសិនបើតម្លៃទីផ្សារនៅចុងការិយបរិច្ឆេទគឺជាតម្លៃទីផ្សារនៅចុងការិយបរិច្ឆេទយថាហេតុ។ ប្រសិនបើលក្ខខណ្ឌត្រូវបានផ្អែកលើតម្លៃទីផ្សារមធ្យមលើរយៈ

ពេលមួយ ដែលបន្ថែមលើសពីចុងការិយបរិច្ឆេទរាយការណ៍មធ្យម នៃការិយបរិច្ឆេទដែលអស់សុពលភាពត្រូវបានប្រើប្រាស់។ ដោយសារតម្លៃទីផ្សារអាចប្រែប្រួល នៅក្នុងការិយបរិច្ឆេទអនាគត ការគណនានៃប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋានមិនរួមបញ្ចូលភាគហ៊ុនធម្មតាដែលអាចបោះផ្សាយ បានជាយថាហេតុរហូតដល់ចុងការិយបរិច្ឆេទយថាហេតុពីព្រោះលក្ខខណ្ឌមិនទាំងអស់ទេដែលត្រូវបានបំពេញចិត្ត។

៥៥ ចំនួនភាគហ៊ុនធម្មតា ដែលអាចបោះផ្សាយបានជាយថាហេតុអាស្រ័យលើប្រាក់ចំណេញអនាគត និងតម្លៃអនាគតនៃភាគហ៊ុនធម្មតា។ នៅក្នុងករណីបែបនេះ ចំនួនភាគហ៊ុនធម្មតា ដែលបានរួមបញ្ចូលនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាបគឺផ្អែកលើលក្ខខណ្ឌទាំងពីរ (ពោលគឺប្រាក់ចំណេញត្រឹមថ្ងៃបិទបញ្ជី និងតម្លៃទីផ្សារបច្ចុប្បន្ន នៅចុងការិយបរិច្ឆេទរាយការណ៍)។ ភាគហ៊ុនធម្មតា ដែលអាចបោះផ្សាយបានជាយថាហេតុ មិនត្រូវបានបញ្ចូលនៅក្នុងការគណនាប្រាក់ចំណេញ ក្នុងមួយភាគហ៊ុនបន្ទាបទេ លុះត្រាលក្ខខណ្ឌទាំងពីរត្រូវបានបំពេញ។

៥៦ នៅក្នុងករណីផ្សេងទៀត ចំនួនភាគហ៊ុនធម្មតាដែលអាចបោះផ្សាយបានជាយថាហេតុអាស្រ័យលើលក្ខខណ្ឌ មួយជាប្រាក់ចំណេញ ឬតម្លៃទីផ្សារ (ឧទាហរណ៍ ការបើកចំនួនជាក់លាក់នៃការលក់រាយ)។ នៅក្នុងករណីបែបនេះ ត្រូវសន្មតថាស្ថានភាពបច្ចុប្បន្ននៃលក្ខខណ្ឌរក្សានៅដដែលរហូតដល់ចុងការិយបរិច្ឆេទយថាហេតុ ភាគហ៊ុនធម្មតាដែលអាចបោះផ្សាយជាយថាហេតុត្រូវបានបញ្ចូល នៅក្នុងការគណនានៃប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាបដោយយោងតាមស្ថានភាពនៅចុងការិយបរិច្ឆេទរាយការណ៍។

៥៧ ភាគហ៊ុនធម្មតា ដែលអាចបោះផ្សាយបានជាយថាហេតុដែលមានសក្តានុ-ពល (ជាជាងភាគហ៊ុនទាំងឡាយ ដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងភាគហ៊ុនយថាហេតុ ដូចជាឧបករណ៍ អាចបំលែងដែលអាចបោះផ្សាយជាយថាហេតុ) ត្រូវបានបញ្ចូលនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាបដូចខាងក្រោមៈ

(ក) អង្គភាពមួយកំណត់ថាតើភាគហ៊ុនធម្មតាដែលមានសក្តានុពល អាចត្រូវបានសន្មតថានឹងអាចបោះផ្សាយបានតាមមូលដ្ឋាននៃលក្ខខណ្ឌដែលបានបញ្ជាក់ ឲ្យការបោះផ្សាយរបស់គេ ដោយអនុលោមតាមបញ្ញត្តិស្តីពីភាគហ៊ុនធម្មតាជាយថាហេតុនៅក្នុងកថាខណ្ឌ ៥២ -៥៦ និង

(ខ) ប្រសិនបើភាគហ៊ុនធម្មតាដែលមានសក្តានុពលទាំងនោះ គួរត្រូវបានឆ្លុះបញ្ចាំង នៅក្នុងប្រាក់ចំណេញ ក្នុងមួយភាគហ៊ុនបន្ទាបអង្គភាពមួយកំណត់ពីផលប៉ះពាល់របស់គេលើការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាបដោយអនុវត្តតាមបញ្ញត្តិទាំងឡាយសម្រាប់សិទ្ធិពិសេសទិញភាគហ៊ុន និងដីកា នៅក្នុងកថាខណ្ឌ ៤៥-៤៨ បញ្ញត្តិសម្រាប់ ឧបករណ៍អាចបំលែងបានតាមកថាខណ្ឌ ៤៩-៥១ បញ្ញត្តិសម្រាប់កិច្ចសន្យា ដែលអាចត្រូវបានទូទាត់ជាភាគហ៊ុនធម្មតា ឬសាច់ប្រាក់តាមកថាខណ្ឌ ៥៨ -៦១ ឬ បញ្ញត្តិផ្សេងទៀតជាការសមស្រប។

ប៉ុន្តែ ការអនុវត្ត ឬការបំលែងគឺត្រូវបានសន្មតសម្រាប់គោលបំណងនៃ ការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនលុះត្រាតែ ការអនុវត្ត

ឬ ការបំលែងនៃភាគហ៊ុនធម្មតាដែលមានសក្តានុពលស្រដៀងគ្នា ដែលកំពុងដំណើរការ ដែលមិនអាចបោះផ្សាយបានជាយថាហេតុ ត្រូវបានគេសន្មត ។

*កិច្ចសន្យាដែលអាចត្រូវបានទូទាត់ជាភាគហ៊ុនឬសាច់ប្រាក់*

៥៨ **នៅពេលដែលអង្គភាពមួយបានបោះផ្សាយកិច្ចសន្យាមួយដែលអាចត្រូវបានទូទាត់ជាភាគហ៊ុនធម្មតា ឬសាច់ប្រាក់តាមសិទ្ធិពិសេសរបស់អង្គភាព អង្គភាពត្រូវសន្មតជាមុនថាកិច្ចសន្យានឹងត្រូវបានទូទាត់ជាភាគហ៊ុនធម្មតា ហើយភាគហ៊ុនធម្មតាដែលមានសក្តានុពលត្រូវបានបញ្ចូលក្នុងការប្រាក់ចំណេញក្នុង មួយភាគហ៊ុនបន្សាបប្រសិនបើឥទ្ធិពលមានបន្សាប។**

៥៩ នៅពេលដែលកិច្ចសន្យាបែបនេះត្រូវបានដាក់បង្ហាញ សម្រាប់គោលបំណងគណនេយ្យ ជាទ្រព្យសកម្ម ឬ បំណុល ឬមានសមាសធាតុមូលធន និងសមាសធាតុបំណុល អង្គភាពត្រូវធ្វើការកែសម្រួលភាគយក សម្រាប់ការប្រែប្រួលក្នុងប្រាក់ចំណេញឬខាតដែលនឹងកើតមានក្នុងកំឡុងការិយ-បរិច្ឆេទប្រសិនបើកិច្ចសន្យាត្រូវបានចាត់ថ្នាក់ទាំងស្រុងជាឧបករណ៍មូល-ធន ។ ការកែសម្រួលគឺស្រដៀង ទៅនឹងការកែសម្រួល ដែលបានតម្រូវឲ្យមាននៅក្នុង កថាខណ្ឌ ៣៣ ។

៦០ **សម្រាប់កិច្ចសន្យាដែលអាចត្រូវបានទូទាត់ជាភាគហ៊ុនធម្មតា ឬជាសាច់ប្រាក់តាមសិទ្ធិពិសេសទិញភាគហ៊ុនរបស់អ្នកកាន់ការបន្សាបច្រើន នៃការទូទាត់សាច់ប្រាក់ និងការទូទាត់ជាភាគហ៊ុនត្រូវបានប្រើ នៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុន។**

៦១ ឧទាហរណ៍នៃកិច្ចសន្យាដែលអាចត្រូវបានទូទាត់ជាភាគហ៊ុនធម្មតា ឬសាច់ប្រាក់គឺជាឧបករណ៍បំណុល ដែលដល់ពេលអវសាន្ត ផ្តល់ឱ្យអង្គភាពនូវសិទ្ធិមិនមានការកម្រិត ដើម្បីទូទាត់ទឹកប្រាក់ដើមជាសាច់ប្រាក់ឬជាភាគ-ហ៊ុនធម្មតាផ្ទាល់ខ្លួន។ ឧទាហរណ៍មួយផ្សេងទៀតគឺជាសិទ្ធិទិញពិសេសដែល មានសរសេរជាលាយលក្ខណ៍អក្សរ ដែលផ្តល់ឱ្យអ្នកកាន់នូវជម្រើសក្នុងការ ទូទាត់ជាភាគហ៊ុនឬជាសាច់ប្រាក់។

*សិទ្ធិពិសេសទិញរួច*

៦២ កិច្ចសន្យា ដូចជាសិទ្ធិទិញពិសេសដែលបានទិញរួច និងសិទ្ធិលក់ពិសេសដែលបានទិញរួច (ពោលគឺ សិទ្ធិពិសេសដែលបានរក្សាដោយអង្គភាពលើភាគហ៊ុនធម្មតាផ្ទាល់ខ្លួន) មិនត្រូវបានបញ្ចូលនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុន ពីព្រោះរួមបញ្ចូលពួកគេអាចជាការការពារការបន្សាប។ សិទ្ធិទិញពិសេសអាច ត្រូវបានអនុវត្តតែប្រសិនបើតម្លៃអនុវត្តខ្ពស់ជាងតម្លៃទីផ្សារ និងសិទ្ធិលក់អាចត្រូវបានអនុវត្ត តែប្រសិនបើតម្លៃលក់ទាបជាងតម្លៃទីផ្សារ ។

*សិទ្ធិទិញពិសេសជាលាយលក្ខណ៍អក្សរ*

**៦៣ កិច្ចសន្យាដែលតម្រូវឱ្យអង្គភាពដើម្បីទិញមកវិញនូវភាគហ៊ុនរបស់ខ្លួន ដូចជា សិទ្ធិទិញពិសេសជាលាយលក្ខណ៍អក្សរ និងកិច្ចសន្យាទិញខាងមុខត្រូវបានឆ្លុះ បញ្ចាំងនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាបប្រសិនបើឥទ្ធិពលមានភាពបន្សាប។ ប្រសិនបើកិច្ចសន្យាទាំង**

នេះគឺស្ថិតនៅជាលុយ ក្នុងកំឡុងការិយបរិច្ឆេទ (ពោលគឺតម្លៃអនុវត្ត ឬតម្លៃទូទាត់គឺលើសតម្លៃមធ្យមទីផ្សារ សម្រាប់ការិយបរិច្ឆេទនោះ ឥទ្ធិពលបន្សាបដែលមានសក្តានុពល លើប្រាក់ចំណេញក្នុងមួយភាគហ៊ុន ត្រូវបានគេគណនាដូចខាងក្រោម:

(ក) គេសន្មតថានៅដើមការិយបរិច្ឆេទមានភាគហ៊ុនធម្មតាគ្រប់គ្រាន់នឹងត្រូវបោះផ្សាយ (តាមតម្លៃ ទីផ្សារមធ្យមក្នុងកំឡុងការិយបរិច្ឆេទ) ដើម្បីបង្កើនចំណូលដើម្បីបំពេញកិច្ចសន្យា

(ខ) គេសន្មតថាចំណូលពីការបោះផ្សាយត្រូវបានប្រើ ដើម្បីបំពេញកិច្ចសន្យា (ពោលគឺដើម្បីទិញត្រឡប់មកវិញនូវភាគហ៊ុនធម្មតា និង

(គ) ភាគហ៊ុនធម្មតាបន្ថែម (ភាពខុសគ្នារវាងចំនួនភាគហ៊ុនធម្មតា ដែលបានសន្មតថាបានបោះផ្សាយ និងចំនួនភាគហ៊ុនធម្មតា ដែលបានទទួលពីការបំពេញកិច្ចសន្យា) ត្រូវបានបញ្ចូលនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាប។

ការកែសម្រួលប្រតិសកម្ម

៦៤ ប្រសិនបើចំនួនភាគហ៊ុនធម្មតា ឬភាគហ៊ុនដែលមានសក្តានុពល ដែលកំពុងដំណើរការកើនឡើងដែលជាលទ្ធផលនៃការធ្វើមូលធនកម្ម ការបោះផ្សាយ លើទឹកប្រាក់បន្ថែម ការបំបែកភាគហ៊ុន ឬការបន្ថយជាលទ្ធផលនៃបញ្ច្រាស់មកវិញនូវការបំបែកភាគហ៊ុន ការគណនាពីប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាននិងបន្សាបសម្រាប់ការិយបរិច្ឆេទទាំងអស់ដែលបានដាក់បង្ហាញត្រូវបានធ្វើការកែសម្រួលប្រតិសកម្ម ។ ប្រសិនបើការផ្លាស់ប្តូរទាំងនេះកើតមានឡើងបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ប៉ុន្តែមុនរបាយ-

ការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឲ្យបោះផ្សាយ នោះការគណនា ក្នុងមួយភាគហ៊ុនសម្រាប់ភាគហ៊ុនទាំងនោះ និងរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ មុនដែលបានដាក់បង្ហាញត្រូវបានផ្អែកលើចំនួន ភាគហ៊ុនថ្មី ។ ហេតុការណ៍ដែលការគណនាក្នុងមួយភាគហ៊ុនឆ្លុះបញ្ចាំងពីការប្រែប្រួលចំនួនភាគហ៊ុនបែបនេះត្រូវបានលាតត្រដាងបង្ហាញ។ លើសពីនេះទៅទៀត ប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន និង បន្សាបនៃការិយបរិច្ឆេទទាំងអស់ដែលបានដាក់បង្ហាញត្រូវបានកែសម្រួលសម្រាប់ឥទ្ធិពលនៃកំហុសឆ្គង និងការកែសម្រួលដែលកើតចេញពីការប្រែប្រួលគោលនយោបាយគណនេយ្យដែលបានធ្វើគណនេយ្យកម្មដាច់ប្រតិសកម្ម ។

៦៥ អង្គភាពមួយមិនបង្ហាញឡើងវិញពីប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាបនៃការិយបរិច្ឆេទមុនដែលបានដាក់ បង្ហាញសំរាប់ការប្រែប្រួលនៅក្នុងការសន្មតដែលបានប្រើនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយហ៊ុន ឬសំរាប់ការបំលែងនៃភាគហ៊ុនធម្មតាដែលមានសក្តានុពលទៅជាភាគហ៊ុនធម្មតា។

## ការដាក់បង្ហាញ

៦៦ អង្គភាពមួយត្រូវបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលលម្អិតនូវប្រាក់ចំណេញ ឬខាតក្នុងមួយភាគហ៊ុនជាមូលដ្ឋាន និងបន្សាបពីកិច្ចប្រតិបត្តិការកំពុងបន្តដែលបែងចែកទៅឲ្យអ្នកកាន់មូលធនធម្មតារបស់អង្គភាពមេ និងសម្រាប់ចំណេញឬខាតដែលបែងចែកទៅឲ្យអ្នកកាន់មូលធនធម្មតារបស់អង្គភាពមេសម្រាប់ការិយបរិច្ឆេទសម្រាប់ថ្នាក់នីមួយៗនៃភាគហ៊ុនធម្មតាដែល មានសិទ្ធិខុសគ្នាចំពោះចំណែកនៅក្នុងប្រាក់ ចំណេញសំរាប់ ការិយ-បរិច្ឆេទ។អង្គភាពមួយត្រូវបង្ហាញប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន

**និង បន្សាប ជាមួយនឹងភាពលេចធ្លោស្មើៗគ្នាសម្រាប់ការិយបរិច្ឆេទទាំងអស់ដែលបានដាក់បង្ហាញ។**

៦៧ ប្រាក់ចំណេញក្នុងមួយភាគហ៊ុន ត្រូវបានដាក់បង្ហាញ សម្រាប់គ្រប់ការិយ-បរិច្ឆេទដែលរបាយការណ៍លទ្ធផលលម្អិតត្រូវបានដាក់បង្ហាញ ។ ប្រសិនបើប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាបត្រូវបានរាយការណ៍សម្រាប់ការិយបរិច្ឆេទយ៉ាងតិចរយៈពេលមួយការិយបរិច្ឆេទ ប្រាក់ចំណេញក្នុងមួយភាគហ៊ុននោះ ត្រូវបានរាយការណ៍សម្រាប់ការិយបរិច្ឆេទទាំងអស់ដែលបានដាក់បង្ហាញ ទោះបីជាប្រាក់ចំណេញ ក្នុងមួយភាគហ៊ុនបន្សាបស្មើនឹងប្រាក់ ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋានក៏ដោយ ។ ប្រសិនបើប្រាក់ចំណេញ ក្នុងមួយភាគហ៊ុនជាមូលដ្ឋាន និងបន្សាបស្មើគ្នា ការបង្ហាញទាំងពីរអាច សម្រេចបាននៅក្នុងបន្ទាត់មួយនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ។

៦៧ក ប្រសិនបើអង្គភាពមួយដាក់បង្ហាញសមាសធាតុនៃរបាយការណ៍ចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ដាច់ដោយឡែកដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៨១ នៃ ស.គ.អ.ក ១ (ដូចបានកែប្រែនៅក្នុងឆ្នាំ ២០០៧) អង្គភាពដាក់បង្ហាញប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាននិងបន្សាបដូចដែលបានតម្រូវឲ្យមាននៅក្នុងកថាខណ្ឌ៦៦និង៦៧ នៅក្នុងរបាយ-ការណ៍ដាច់ដោយឡែកនោះ។

**៦៨ អង្គភាពមួយដែលរាយការណ៍ពីកិច្ចប្រតិបត្តិការមិនបន្តត្រូវលាតត្រដាងទឹកប្រាក់ក្នុងមួយភាគហ៊ុនជាមូលដ្ឋាន និងបន្សាបសម្រាប់កិច្ចប្រតិបត្តិការមិនបន្តនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ឬនៅក្នុងកំណត់សម្គាល់ ។**

៦៨ក ប្រសិនបើអង្គភាពមួយដាក់បង្ហាញសមាសធាតុនៃរបាយការណ៍ចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ដាច់ដោយឡែកដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៨១ នៃ ស.គ.អ.ក ១ (ដូចបានកែប្រែនៅក្នុង ឆ្នាំ២០០៧) អង្គភាពដាក់បង្ហាញប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាននិងបន្សាបសម្រាប់កិច្ចប្រតិបត្តិការមិនបន្ត ដូចបានតម្រូវឱ្យមាននៅក្នុងកថាខណ្ឌ ៦៨ នៅក្នុងរបាយការណ៍ដាច់ដោយឡែកនោះ ឬនៅក្នុងកំណត់សម្គាល់ ។

**៦៩ អង្គភាពមួយត្រូវបង្ហាញប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន និងបន្សាប ទោះបីជាទឹកប្រាក់អវិជ្ជមាន (ពោលគឺ ការខាតក្នុងមួយភាគហ៊ុន)។**

## ការលាតត្រដាងព័ត៌មាន

**៧០ អង្គភាពមួយត្រូវលាតត្រដាងដូចខាងក្រោមៈ**

(ក) ទឹកប្រាក់ដែលបានប្រើជាភាគយកនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន និងបន្សាប និងការសម្របសម្រួលនៃទឹកប្រាក់ទាំងនោះទៅរបាយការណ៍ចំណេញ ឬខាតដែលបែងចែកទៅឱ្យអង្គភាពមេសម្រាប់ការិយបរិច្ឆេទ។ ការសម្របសម្រួលត្រូវបញ្ចូល ឥទ្ធិពលមួយៗនៃថ្នាក់នីមួយ នៃឧបករណ៍ដែលប៉ះពាល់ដល់ប្រាក់ចំណេញក្នុងមួយភាគហ៊ុន។

(ខ) ចំនួនភាគហ៊ុនមធ្យមដែលបានប្រើជាភាគបែងនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាននិងបន្សាប និងការសម្របសម្រួលនៃភាគបែងទៅវិញទៅមក។ ការសម្របសម្រួលត្រូវបញ្ចូលឥទ្ធិពលមួយៗនៃថ្នាក់នីមួយៗនៃឧបករណ៍ដែលប៉ះពាល់ប្រាក់ចំណេញក្នុងមួយភាគហ៊ុន។

(គ) ឧបករណ៍ (រួមបញ្ចូលទាំងភាគហ៊ុនដែលអាចបោះផ្សាយជាយថាហេតុ) ដែលអាចបន្ស៊ាបប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាននាពេលអនាគត ប៉ុន្តែត្រូវបានបញ្ចូលនៅក្នុងការគណនានៃប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ស៊ាបពីព្រោះពួកគេគឺជាការការពារការបន្ស៊ាបសម្រាប់ការិយបរិច្ឆេទដែលបានដាក់បង្ហាញ។

(ឃ) ការបរិយាយពីប្រតិបត្តិការជាភាគហ៊ុនធម្មតា ឬប្រតិបត្តិការជាភាគហ៊ុនធម្មតាដែលមានសក្តានុពលក្រៅពីប្រតិបត្តិការ ដែលត្រូវបានធ្វើគណនេយ្យកម្មដោយអនុលោមតាមកថាខណ្ឌ ៦៤ ដែលកើតឡើងបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ និងដែលអាចប្រែប្រួលជាសំខាន់នូវចំនួនភាគហ៊ុនធម្មតា ឬភាគហ៊ុនធម្មតាដែលមានសក្តានុពលដែលកំពុងដំណើរការនៅចុងការិយបរិច្ឆេទប្រសិនបើប្រតិបត្តិការទាំងនោះបានកើតឡើងមុនចុងការិយបរិច្ឆេទរាយការណ៍។

៧១ ឧទាហរណ៍នៃប្រតិបត្តិការនៅក្នុងកថាខណ្ឌ ៧០(ឃ) រួមបញ្ចូលៈ

(ក) ការបោះផ្សាយភាគហ៊ុនសម្រាប់សាច់ប្រាក់

(ខ) ការបោះផ្សាយភាគហ៊ុននៅពេលដែលចំណូលត្រូវបានប្រើប្រាស់ដើម្បីសងបំណុល ឬភាគហ៊ុនអាទិភាព ដែលកំពុងដំណើរការនៅចុងការិយបរិច្ឆេទរាយការណ៍

(គ) ការហៅត្រឡប់វិញនៃភាគហ៊ុនធម្មតាកំពុងដំណើរការ

(ឃ) ការបំលែង ឬការអនុវត្តនៃភាគហ៊ុនធម្មតា ដែលមានសក្តានុពលដែលកំពុងដំណើរនៅចុងការិយបរិច្ឆេទរាយការណ៍ទៅជាភាគហ៊ុនធម្មតា

(ង) ការបោះផ្សាយសិទ្ធិពិសេសដីកា ឬឧបករណ៍អាចបំលែងបាន និង

(ច) ការសម្រេចបាននូវលក្ខខណ្ឌ ដែលនាំឲ្យមានការបោះផ្សាយភាគហ៊ុនដែលអាចបោះផ្សាយបានជា យថាហេតុ។

ទឹកប្រាក់ចំណេញក្នុងមួយភាគហ៊ុនមិនត្រូវបានកែសម្រួលសម្រាប់ប្រតិបត្តិការបែបនេះដែលបានកើតឡើង បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ពីព្រោះ ប្រតិបត្តិការបែបនេះ មិនប៉ះពាល់ដល់ទឹកប្រាក់នៃដើមទុនដែលបានប្រើ ដើម្បីផលិតចំណេញឬខាតសម្រាប់កាលបរិច្ឆេទ។

៧២ ឧបករណ៍ហិរញ្ញវត្ថុ និងកិច្ចសន្យាផ្សេងទៀតដែលបង្កើតនូវភាគហ៊ុនធម្មតាដែលមានសក្តានុពលអាចបញ្ចូលលក្ខខណ្ឌ ដែលប៉ះពាល់ការវាស់វែងនៃប្រាក់ចំណេញក្នុងមួយភាគហ៊ុន ជាមូលដ្ឋាននិងបន្សាប។ លក្ខខណ្ឌទាំងនេះអាចកំណត់ថាតើ ភាគហ៊ុនធម្មតាដែលមានសក្តានុពលមានលក្ខណៈបន្សាប និងប្រសិនបើដូច្នេះមែននោះ ឥទ្ធិពលលើចំនួនមធ្យមនៃភាគហ៊ុនដែលកំពុងដំណើរការ និងការកែសម្រួលបន្តបន្ទាប់ណាមួយ ចំពោះប្រាក់ចំណេញ ឬខាត ដែលបែងចែកទៅឲ្យអ្នកកាន់មូលធនធម្មតា។ ការលាតត្រដាងពីលក្ខខណ្ឌនៃ ឧបករណ៍ហិរញ្ញវត្ថុបែបនេះ និងកិច្ចសន្យាផ្សេងទៀតគឺត្រូវបានលើកទឹកចិត្ត ប្រសិនបើ មិនដូច្នេះទេត្រូវបានតម្រូវ (សូមមើល ស.រ.ហ.អ.ក ៧ *ឧបករណ៍ហិរញ្ញវត្ថុៈការលាតត្រដាង*)។

៧៣ **ប្រសិនបើអង្គភាពលាតត្រដាង បន្ថែមលើប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន និងបន្សាបទឹកប្រាក់ក្នុងមួយភាគហ៊ុន ដោយប្រើសមាសធាតុដែលបានរាយការណ៍រួចនៃរបាយការណ៍លទ្ធផលលម្អិត ជាជាងទឹកប្រាក់ដែលបានតម្រូវដោយអង្គភាពនេះ ទឹកប្រាក់បែបនេះត្រូវបានគណនា**

ដោយ ប្រើចំនួនភាគហ៊ុនមធ្យម នៃភាគហ៊ុនធម្មតាដែលបានកំណត់ ដោយអនុលោមតាមស្តង់ដានេះ។ ទឹកប្រាក់ក្នុងមួយភាគហ៊ុនជាមូលដ្ឋាន និងបន្សាបដែលទាក់ទិននឹងសមាសធាតុបែបនេះត្រូវបានលាតត្រដាងជាមួយនឹងភាគលេចឆ្លោស្មើគ្នា និងត្រូវបានដាក់បង្ហាញនៅក្នុងកំណត់សម្គាល់។ អង្គភាពមួយត្រូវបង្ហាញពីមូលដ្ឋានដែលត្រូវបាន កំណត់ដោយរួមបញ្ចូលថាតើទឹកប្រាក់ក្នុងមួយភាគគឺមុនការបង់ពន្ធ ឬក្រោយការបង់ពន្ធ។ ប្រសិនបើសមាសធាតុនៃរបាយការណ៍លទ្ធផលលម្អិតត្រូវបានប្រើ ដែលមិនត្រូវបានរាយការណ៍ជាបន្ទាត់គណនី នៅក្នុងរបាយការណ៍លទ្ធផល លម្អិត ការសម្របសម្រួលត្រូវបានផ្តល់រវាងសមាសធាតុដែលបានប្រើ និងបន្ទាត់គណនីដែលត្រូវបានរាយការណ៍នៅក្នុងលទ្ធផលលម្អិត ។

៧៣ក កថាខណ្ឌ ៧៣ ក៏អនុវត្តចំពោះអង្គភាពមួយដែលលាតត្រដាង បន្ថែមលើប្រាក់ចំណេញក្នុងមួយភាគហ៊ុន ធម្មតាជាមូលដ្ឋាននិងបន្សាប ទឹកប្រាក់ក្នុងមួយភាគហ៊ុនដោយប្រើសមាសធាតុនៃរបាយការណ៍លទ្ធផលដាច់ដោយឡែក (ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៨១ នៃ ស.គ.អ.ក ១ (ដូចបានកែប្រែនៅក្នុង ឆ្នាំ២០០៧)) ក្រៅពីទឹកប្រាក់ដែលបានតម្រូវ ដោយស្តង់ដានេះ។

## កាលបរិច្ឆេទប្រសិទ្ធ

៧៤ អង្គភាពមួយត្រូវអនុវត្តស្តង់ដានេះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ។ ការអនុវត្តមុនត្រូវបានលើកទឹកចិត្ត ។ ប្រសិនបើអង្គភាពមួយប្រើស្តង់ដានេះសម្រាប់

កាិរយបរិច្ឆេទដែលចាប់ផ្ដើម មុនថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ ។

៧៤ក ស.គ.អ.ក ១ (ដូចបានកែប្រែនៅក្នុង ឆ្នាំ២០០៧) បានធ្វើវិសោធនកម្មវាក្យសព្ទដែលបានប្រើទូទាំង ស.រ.ហ.អ.ក។ លើសពីនេះទៅទៀត វាបានបន្ថែមកថាខណ្ឌ ៤ក ៦៧ក ៦៨ក និង ៧៣ក។ អង្គភាពមួយ ត្រូវអនុវត្តវិសោធនកម្មទាំងនោះសម្រាប់កាិរយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្ដើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៩។ ប្រសិនបើ អង្គភាពមួយអនុវត្ត ស.គ.អ.ក ១ (បានកែប្រែឆ្នាំ ២០០៧) សម្រាប់ការកាិរយបរិច្ឆេទមុនវិសោធនកម្មត្រូវបានប្រើសម្រាប់កាិរយបរិច្ឆេទមុននោះ។

## ការដកចេញសេចក្ដីប្រកាសផ្សេងទៀត

៧៥ ស្ដង់ដានេះជំនួសឲ្យ ស.គ.អ.ក ៣៣*ប្រាក់ចំណេញក្នុងមួយភាគហ៊ុន* (បានបោះផ្សាយនៅក្នុងឆ្នាំ១៩៩៧)។

៧៦ ស្ដង់ដានេះជំនួស គ.ប.ស -២៤ *ប្រាក់ចំណេញ ក្នុងមួយភាគហ៊ុនឧបករណ៍ហិរញ្ញវត្ថុ និងកិច្ចសន្យាផ្សេងទៀតដែលអាចត្រូវបានទូទាត់ជាភាគហ៊ុន។*

## ឧបសម្ព័ន្ធ ក

## សេចក្ដីណែនាំពីការអនុវត្ត

*ឧបសម្ព័ន្ធនេះគឺជាផ្នែកសំខាន់មួយនៃស្ដង់ដា។*

### ប្រាក់ចំណេញឬខាតដែលបែងចែកទៅឲ្យអង្គភាពមេ

ក១ សម្រាប់គោលបំណងនៃការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុន ដែលផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួម ប្រាក់ចំណេញ ឬខាត ដែលបែងចែក

ទៅឲ្យអង្គភាពមេ សំដៅដល់ប្រាក់ចំណេញ ឬខាត នៃអង្គភាពរួមបន្ទាប់ពីកែសម្រួលសម្រាប់ភាគកម្មអប្បបភាគ។

**ការបោះផ្សាយសិទ្ធិ**

ក២ ការបោះផ្សាយភាគហ៊ុនធម្មតានៅពេលអនុវត្តឬការបំលែងភាគហ៊ុនធម្មតាដែលមានសក្តានុពលជាទូទៅមិន ផ្តល់នូវការកើនឡើងចំពោះសមាសធាតុប្រាក់បន្ថែមទេ។ នេះដោយសារតែ ភាគហ៊ុនធម្មតាដែលមានសក្តានុពលជាទូទៅត្រូវបានបោះផ្សាយជាតម្លៃពេញ ដែលនាំដល់ការប្រែប្រួលតាមសមាមាត្រនៅក្នុងធនធាន ដែលអាចរកបានចំពោះអង្គភាព។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការបោះផ្សាយសិទ្ធ តម្លៃអនុវត្តជារឿយៗតិចជាងតម្លៃសមស្របនៃភាគហ៊ុន។ដូច្នេះដូចបានកំណត់ចំណាំនៅក្នុងកថាខណ្ឌ ២៧(ខ) ការបោះផ្សាយសិទ្ធបែបនេះរួមបញ្ចូលទាំងសមាសធាតុប្រាក់បន្ថែម ។ ប្រសិនបើការបោះផ្សាយសិទ្ធិត្រូវបានផ្តល់ទៅឲ្យម្ចាស់ភាគហ៊ុន ដែលមានស្រាប់ទាំងអស់នៃចំនួនភាគហ៊ុនធម្មតាដែលត្រូវប្រើក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន និងបន្ទាបសម្រាប់ការិយបរិច្ឆេទទាំងអស់មុនការបោះផ្សាយសិទ្ធិ គឺជាចំនួនភាគហ៊ុនធម្មតាដែលកំពុងដំណើរការមុនការបោះផ្សាយដោយគុណនឹងកត្តាដូចខាងក្រោមៈ

$$\frac{\text{តម្លៃសមស្របក្នុងមួយភាគហ៊ុនភ្លាមៗមុនការអនុវត្តសិទ្ធិ}}{\text{តម្លៃសមស្របមុនការអនុវត្តសិទ្ធិក្នុងមួយភាគហ៊ុន}}$$

តម្លៃសមស្របមុនអនុវត្តសិទ្ធិក្នុងមួយភាគហ៊ុនត្រូវបានគណនាដោយការបូកតម្លៃទីផ្សារសរុបនៃភាគហ៊ុន ភ្លាមៗមុនការអនុវត្តសិទ្ធិចំពោះចំណូល

ពីការអនុវត្តសិទ្ធិ និងចែកដោយចំនួនភាគហ៊ុនដែលកំពុងដំណើរការបន្ទាប់ពីការអនុវត្តសិទ្ធ។ នៅពេលណាសិទ្ធិនឹងត្រូវបានធ្វើការជួញដូរជាសាធារៈណៈដាច់ដោយឡែកពីភាគហ៊ុនមុនកាលបរិច្ឆេទអនុវត្ត តម្លៃសមស្រប សម្រាប់គោលបំណងនៃការគណនានេះត្រូវបានបង្កើតឡើងតាមថ្ងៃបិទចុងក្រោយលើភាគហ៊ុនដែលត្រូវបានជួញដូររួមជាមួយនឹងសិទ្ធិ ។

## លេខគ្រប់គ្រង

ក៣ ដើម្បីពន្យល់ពីការអនុវត្តសញ្ញាណលេខគ្រប់គ្រងដែលបានរៀបរាប់ នៅក្នុងកថាខណ្ឌ ៤២ និង ៤៣ ត្រូវសន្មតថាអង្គភាពមួយមានប្រាក់ចំណេញពីកិច្ចប្រតិបត្តិការបន្តដែលបែងចែកទៅឲ្យអង្គភាពមេ តម្លៃ CU ៤៨០០* ការខាតពីកិច្ចប្រតិបត្តិការមិនបន្តដែលបែងចែក ទៅឲ្យអង្គភាពមេតម្លៃ ៧២០០ ការខាតដែលបែងចែកទៅឲ្យអង្គភាពមេ ២៤០០ និង ភាគហ៊ុនធម្មតាចំនួន២០០០ និងភាគហ៊ុនធម្មតាអាទិភាព ៤០០ កំពុងដំណើរការ។ ប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់អង្គភាពជាមូលដ្ឋានតម្លៃ CU២.៤០ សម្រាប់កិច្ចប្រតិបត្តិការបន្ត តម្លៃ CU៣.៦០ សម្រាប់កិច្ចប្រតិបត្តិការមិនបន្ត និងតម្លៃ CU១.២០ សម្រាប់ការខាត ។ ភាគហ៊ុនធម្មតាដែលមានសក្តានុពល ចំនួន ៤០០ ត្រូវបានបញ្ចូលនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាបពីព្រោះប្រាក់ចំណេញក្នុងមួយភាគហ៊ុន CU២.០០ សំរាប់កិច្ចប្រតិបត្តិការបន្តមានភាពបន្សាប ដោយសន្មតថាមិនមានប្រាក់ចំណេញ ឬ ខាត ប៉ះពាល់ដល់ភាគហ៊ុនធម្មតា ដែលមានសក្តានុពលចំនួន ៤០០ នោះទេ ។ ដោយសារតែប្រាក់ចំណេញពីកិច្ចប្រតិបត្តិការ

បន្តដែលបែងចែកទៅ អង្គភាពមេគឺជាលេខគ្រប់គ្រងគឺជាលេខគ្រប់គ្រង អង្គភាពក៏ត្រូវបញ្ចូល ភាគហ៊ុនធម្មតាដែលមានសក្តានុពល ចំនួន៤០០ ទាំងនោះ នៅក្នុងការគណនាទឹកប្រាក់ចំណេញក្នុងមួយភាគហ៊ុនផ្សេងទៀត ទោះបីជាទឹកប្រាក់ ចំណេញក្នុងមួយភាគហ៊ុនដែលកើតឡើងគឺជាការការពារការបន្ទាបចំពោះប្រាក់ចំណេញ ក្នុងមួយភាគហ៊ុនជាមូលដ្ឋានដែលអាចប្រៀបធៀបបាន ពោលគឺការខាតក្នុងមួយភាគហ៊ុនដកចេញ (CU៣.០០) ក្នុងមួយភាគហ៊ុន សម្រាប់ការខាតពី កិច្ចប្រតិបត្តិការមិនបន្តនិង (CU១.០០) ក្នុងមួយ ភាគហ៊ុនសម្រាប់ការខាត

## តម្លៃទីផ្សារមធ្យមនៃភាគហ៊ុនធម្មតា

ក៤ សម្រាប់គោលបំណងនៃការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប តម្លៃទីផ្សារមធ្យមនៃភាគហ៊ុន ធម្មតាដែលបានសន្មតថានឹងត្រូវបោះផ្សាយ ត្រូវបានគណនា តាមមូលដ្ឋានតម្លៃទីផ្សារមធ្យមនៃភាគហ៊ុនធម្មតា ក្នុងកំឡុងការិយបរិច្ឆេទ។ តាមទ្រឹស្តី គ្រប់ប្រតិបត្តិការទីផ្សារ សម្រាប់ភាគហ៊ុនធម្មតារបស់អង្គភាពអាចត្រូវបានបញ្ចូលនៅក្នុងការកំណត់ពីតំលៃទីផ្សារមធ្យម ។ ប៉ុន្តែជាកិច្ចការប្រតិបត្តិ តម្លៃមធ្យមធម្មតា ប្រចាំសប្តាហ៍ ប្រចាំខែគឺទូទៅគ្រប់គ្រង។

ក៥ ជាទូទៅតម្លៃទីផ្សារនៅពេលបិទគឺគ្រប់គ្រាន់សម្រាប់ការគណនាតម្លៃទីផ្សារមធ្យម ។ តែទោះបីជាយ៉ាងក៏ដោយ នៅពេលដែលតម្លៃឡើងចុះយ៉ាងទូលាយនោះ មធ្យមនៃតម្លៃខ្ពស់និងតម្លៃទាបជាធម្មតាបង្កើត តម្លៃដែលអាចតំណាងបានច្រើន ។ វិធីសាស្រ្ត ដែលបានប្រើ ដើម្បីគណនាតម្លៃ

ទីផ្សារមធ្យម គឺត្រូវបានប្រើប្រកបដោយ សង្គតិភាពលុះត្រាតែវាលែងតំណាងឲ្យតទៅទៀតដោយសារតែលក្ខខណ្ឌបានប្រែប្រួល។ ឧទាហរណ៍ អង្គភាពមួយដែលប្រើតម្លៃទីផ្សារពេលបិទដើម្បីគណនាតម្លៃទីផ្សារមធ្យមត សម្រាប់រយៈពេលច្រើនឆ្នាំនៃតម្លៃដែលមានស្ថេរភាពអាចផ្លាស់ប្តូរ ចំពោះមធ្យមនៃតម្លៃខ្ពស់និងតម្លៃទាប ប្រសិនបើតម្លៃ ចាប់ផ្តើមឡើងចុះយ៉ាងខ្លាំង និងតម្លៃទីផ្សារពេលបិទលែងបង្កើតតម្លៃមធ្យម ដែលអាចតំណាងបានតទៅទៀត។

## សិទ្ធិពិសេស ដីកា និង សមមូលរបស់ពួកគេ

ក៦ សិទ្ធិពិសេស ឬដីកា ដើម្បីទិញឧបករណ៍អាចបំលែងបាន ត្រូវបានសន្មតថានឹងត្រូវអនុវត្តដើម្បីទិញ ឧបករណ៍អាចបំលែងបាន នៅពេលណាដែលតម្លៃមធ្យមនៃឧបករណ៍អាចបំលែងបានទាំងពីរ និងភាគហ៊ុនធម្មតា ដែលអាចទទួលបាន នៅពេលបំលែងមានតម្លៃលើសពីតម្លៃអនុវត្ត នៃសិទ្ធិពិសេស ឬដីកា។ ប៉ុន្តែ ការអនុវត្តមិនត្រូវបានសន្មត លុះត្រាតែការបំលែងនៃឧបករណ៍អាចបំលែងបានស្រដៀងគ្នាដែលកំពុងដំណើរការ ប្រសិនបើមានក៏ត្រូវបានគេសន្មតផងដែរ។

ក៧ សិទ្ធិពិសេស ឬដីកាអាចអនុញ្ញាត ឬតម្រូវឲ្យមានការស្នើតសុំទិញឧបករណ៍ បំណុលឬឧបករណ៍ផ្សេងទៀតរបស់អង្គភាព (ឬក្រុមហ៊ុនមេ ឬក្រុមហ៊ុន បុត្រសម្ព័ន្ធ)នៅក្នុងការទូទាត់នៃចំណែកទាំងអស់ឬមួយចំណែកនៃតម្លៃអនុវត្ត។ នៅក្នុងការគណនានៃប្រាក់ចំណេញក្នុងមួយភាគហ៊ុនសិទ្ធិពិសេស ឬដីកាទាំងនោះមាន ឥទ្ធិពលបន្ស៊ាបប្រសិនបើ (ក) តម្លៃទីផ្សារ

មធ្យម នៃភាគហ៊ុនធម្មតាទាក់ទិនសម្រាប់ការិយបរិច្ឆេទលើសពី តម្លៃអនុវត្ត ឬ (ខ) តម្លៃលក់នៃឧបករណ៍ដែលត្រូវស្នើសុំគឺស្ថិតនៅក្រោមតម្លៃដែលឧបករណ៍អាចត្រូវ បានស្នើសុំក្រោមកិច្ចព្រមព្រៀងសិទ្ធិពិសេស ឬដីកា និងតម្លៃអប្បហារបង្កើតឲ្យមានតម្លៃអនុវត្តដ៏មាន ប្រសិទ្ធភាពក្រោមតំលៃទីផ្សារនៃភាគហ៊ុនធម្មតា ដែលអាចទទួលបាននៅពេលអនុវត្ត ។ នៅក្នុងការគណនា នៃប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាប សិទ្ធិពិសេស ឬដីកាទាំងនោះ ត្រូវបានសន្មតថានឹងត្រូវបានអនុវត្ត និងឧបករណ៍បំណុល ឬឧបករណ៍ផ្សេងទៀតត្រូវបានសន្មតថានឹងត្រូវបានស្នើសុំ ។ ប្រសិនបើសាច់ប្រាក់ ដែលបានស្នើសុំមានគុណសម្បត្តិច្រើនចំពោះអ្នកកាន់សិទ្ធិពិសេស ឬ ដីកា ហើយកិច្ចសន្យាអនុញ្ញាតឲ្យមានការស្នើសុំសាច់ប្រាក់ ការស្នើសុំសាច់ប្រាក់ ត្រូវបានសន្មតថានឹងកើតមាន។ ការប្រាក់ (ក្រោយការបង់ពន្ធ) លើបំណុលណាបានសន្មតដែលនឹងត្រូវបានស្នើសុំត្រូវបានបូកបញ្ចូលត្រឡប់មកវិញជាការកែសម្រួលចំពោះភាគយក ។

ក៨ ការទទួលស្គាល់ស្រដៀងគ្នាមួយ ត្រូវបានផ្តល់ ចំពោះភាគហ៊ុនអាទិភាពដែលមានបញ្ញត្តិស្រដៀងគ្នា ឬចំពោះ ឧបករណ៍ផ្សេងទៀត ដែលមានសិទ្ធិពិសេសបំលែង ដែលអាចអនុញ្ញាតឲ្យអ្នកវិនិយោគ បង់សាច់ប្រាក់សម្រាប់ អត្រាបំលែងដែលមានលក្ខណៈល្អប្រសើរច្រើនជាង។

ក៩ លក្ខខណ្ឌនៃសិទ្ធិពិសេស ឬដីកាដែលកំពុងមានអាចតម្រូវឲ្យចំណូលដែល បានទទួលពីការអនុវត្តឧបករណ៍ទាំងនោះ ដែលនឹងត្រូវបានប្រើដើម្បី ហៅមកវិញនូវឧបករណ៍បំណុល ឬបំណុលផ្សេងទៀតរបស់អង្គភាព

(ឬ ក្រុមហ៊ុនមេ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ) ។ នៅក្នុងការគណនានៃប្រាក់ចំណេញ ក្នុងមួយភាគហ៊ុនបន្ទាប សិទ្ធិពិសេស ឬដីកាទាំងនោះត្រូវបានសន្មតថា នឹងត្រូវបានអនុវត្ត និងចំណូលដែលបានប្រើដើម្បីទិញបំណុលតាមតម្លៃទីផ្សារមធ្យមជាជាងទិញភាគហ៊ុនធម្មតា ។ ប៉ុន្តែចំណុលដែលលើសដែល មានទទួលពីការអនុវត្តដែលបានសន្មតលើទឹកប្រាក់ ដែលបានប្រើសម្រាប់ ការទិញបំណុលដែលមានសន្មតត្រូវបានគិតចូល (ពោលសន្មតថានឹងត្រូវ ប្រើ ដើម្បីទិញមកវិញនូវភាគហ៊ុនធម្មតា) នៅក្នុងការគណនា នៃប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប ។ ការប្រាក់ (ក្រោយការបង់ពន្ធ) លើបំណុលណាមួយបានសន្មតរួច ដែលនឹងត្រូវបានទិញត្រូវបានបូកបញ្ចូល ត្រឡប់មកវិញជាការកែសម្រួលចំពោះភាគយក ។

## សិទ្ធិទិញពិសេសជាលាយលក្ខណ៍អក្សរ

ក១០ ដើម្បីពន្យល់ពីការអនុវត្តនៃកថាខណ្ឌ ៦៣ សន្មតថាអង្គភាពមួយមានសិទ្ធិទិញពិសេសជាលាយលក្ខណ៍អក្សរ លើភាគហ៊ុនធម្មតារបស់ខ្លួន ជាមួយនឹង តម្លៃអនុវត្ត CU៣៥។ តម្លៃទីផ្សារមធ្យមនៃតម្លៃភាគហ៊ុនធម្មតារបស់ខ្លួន សម្រាប់ការិយបរិច្ឆេទគឺ CU២៨ ។ នៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប អង្គភាពសន្មត់ថាអង្គភាពបានបោះផ្សាយ ១៥០ ភាគហ៊ុន ក្នុងតម្លៃ CU២៨ក្នុងភាគហ៊ុននៅដើមការិយបរិច្ឆេទដើម្បីបំពេញកាតព្វកិច្ចទិញរបស់ខ្លួនតម្លៃ CU៤.២០០។ ភាពខុសគ្នារវាង ភាគហ៊ុនធម្មតា ១៥០ ដែលបានបោះផ្សាយ និងភាគហ៊ុនធម្មតា ១២០ ដែលបានទទួលពីការបំពេញចិត្តសិទ្ធិទិញពិសេស (ភាគហ៊ុនធម្មតាបន្ថែម ចំនួន៣០)

ត្រូវបានបូកបញ្ចូលទៅក្នុងភាគបែងនៅក្នុងការគណនាប្រាក់ចំណេញ ក្នុងមួយភាគបន្សាប។

**ឧបករណ៍ទាំងឡាយរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រោមហ៊ុនរួមទុន ឬសមាគត**

ក១១ ភាគហ៊ុនធម្មតាដែលមានសក្តានុពលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន ឬសមាគតដែលអាចបំលែងបាន ទៅជាភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន ឬសមាគត ឬភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនមេ ភាគីរួមទុន ឬអ្នកវិនិយោគ (អង្គភាពរាយការណ៍) ត្រូវបានបញ្ចូលនៅក្នុងការគណនា ប្រាក់ចំណេញក្នុងមួយភាគបន្សាប ដូចខាងក្រោមៈ

(ក) ឧបករណ៍ទាំងឡាយដែលបានបោះផ្សាយដោយក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន ឬសមាគត ដែលផ្តល់លទ្ធភាព ឱ្យអ្នកកាន់ឧបករណ៍របស់គេដើម្បីទទួលបាននូវភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន ឬសមាគត។ ប្រាក់ចំណេញក្នុងមួយភាគហ៊ុនទាំងនោះបន្ទាប់មក ត្រូវបានបញ្ចូលនៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់អង្គភាពរាយការណ៍ដែលផ្អែកលើការកាន់កាប់ នៃឧបករណ៍របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន ឬសមាគត។

(ខ) ឧបករណ៍ទាំងឡាយ របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន ឬសមាគតដែលអាចបំលែងទៅជា ភាគហ៊ុនធម្មតារបស់អង្គភាពរាយការណ៍ ត្រូវបានយកទៅគិតក្នុងចំណោមភាគហ៊ុនធម្មតាដែលមានសក្តានុពលរបស់អង្គភាពរាយការណ៍សម្រាប់គោលបំណងនៃការគណនាប្រាក់ចំណេញ ក្នុងមួយភាគហ៊ុនបន្សាប។ ដូចគ្នានេះដែរ សិទ្ធិ

ពិសេស ឬដីកាដែលបានចេញផ្សាយ ដោយក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន ឬសមាគត ដើម្បីទិញភាគហ៊ុនធម្មតារបស់អង្គភាពរាយការណ៍ត្រូវបានគិតចូលក្នុងចំណោមភាគហ៊ុនធម្មតា ដែលមានសក្តានុពលរបស់អង្គភាពរាយការណ៍ នៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្សាបរួម។

ក១២ សម្រាប់គោលបំណង នៃការកំណត់ពីឥទ្ធិពលប្រាក់ចំណេញ ក្នុងមួយភាគហ៊ុននៃឧបករណ៍ ដែលបានបោះផ្សាយដោយអង្គភាពរាយការណ៍ ដែលអាចបំលែងបានទៅជាភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន សមាគត ឧបករណ៍ទាំងឡាយត្រូវបានសន្មតថានឹងត្រូវបានបំលែង ហើយភាគយក (ប្រាក់ចំណេញ ឬខាត ដែលបែងចែកទៅឲ្យអ្នកកាន់មូលដ្ឋានធម្មតារបស់អង្គភាពមេ) ត្រូវបានកែសម្រួលជាការចាំបាច់ ដោយអនុលោមតាម កថាខណ្ឌ ៣៣។ បន្ថែមទៅលើការសម្រួលទាំងនោះ ភាគយកត្រូវបានកែសម្រួលសម្រាប់ការផ្លាស់ប្តូរណាមួយនៅក្នុងប្រាក់ចំណេញ ឬ ខាត ដែលបានកត់ត្រាដោយអង្គភាពរាយការណ៍ (ដូចជាចំណូលពី ភាគលាភ ឬចំណូលពីវិធីសាស្រ្តមូលធន) ដែលត្រូវបានបែងចែក ដើម្បីបង្កើននៅក្នុង ចំនួនភាគហ៊ុនធម្មតារបស់អង្គភាពបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន សមាគត ដែលកំពុងដំណើរការ ដែលជាលទ្ធផលនៃការបំលែង ដែលបានសន្មត។ ភាគបែងនៃការគណនាប្រាក់ចំណេញ ក្នុងមួយភាគហ៊ុនបន្សាបមិនត្រូវបានប៉ះពាល់ ដោយសារតែចំនួនភាគហ៊ុនធម្មតា របស់អង្គភាពរាយការណ៍ដែលកំពុងដំណើរការនឹងមិនប្រែប្រួលនៅពេលមានការបំលែងបានសន្មតនោះទេ ។

## ការចូលរួមឧបករណ៍មូលធន និង ភាគហ៊ុនធម្មតាដែលមានពីរថ្នាក់

ក១៣ មូលធនរបស់អង្គភាពមួយចំនួនរួមបញ្ចូលៈ

(ក) ឧបករណ៍ ដែលចូលរួមនៅក្នុងភាគលាភជាមួយនឹង ភាគហ៊ុនធម្មតាដោយយោងតាមរូបមន្តកំណត់ទុកមុន (ជាឧទាហរណ៍ ពីរសម្រាប់មួយ) ដែលមានការកម្រិតខ្ពស់ តាមទំហំនៃការចូលរួម (ឧទាហរណ៍ ត្រឹមតែមិនលើសទឹកប្រាក់ដែលបានកំណត់ក្នុងមួយភាគហ៊ុនឡើយ)។

(ខ) ថ្នាក់មួយនៃភាគហ៊ុនធម្មតា ដែលមានអត្រាភាគលាភខុសគ្នាពីអត្រានៃថ្នាក់មួយផ្សេងទៀតនៃភាគហ៊ុនធម្មតា ប៉ុន្តែដោយគ្មានបុព្វសិទ្ធិ ឬបុព្វសិទ្ធិដែលមានវ័យចំណាស់។

ក១៤ សម្រាប់គោលបំណងនៃការគណនាប្រាក់ចំណេញក្នុងមួយបន្សាបការ-បំលែងត្រូវបានសន្មត សម្រាប់ឧបករណ៍ទាំងនោះ ដែលបានបរិយាយនៅក្នុង កថាខណ្ឌ ក១៣ ដែលអាចបំលែងទៅជាភាគហ៊ុនធម្មតាប្រសិនបើឥទ្ធិពលមានភាពបន្សាប ។ សម្រាប់ឧបករណ៍ទាំងនោះដែលមិនអាចបំលែងបានទៅជាថ្នាក់មួយនៃភាគហ៊ុនធម្មតាមប្រាក់ចំណេញ ឬខាតសម្រាប់ការិយបរិច្ឆេទ ត្រូវបានបែងចែកទៅជាថ្នាក់ផ្សេងទៀត នៃភាគហ៊ុន និងការចូលរួម ឧបករណ៍មូលធនដោយអនុលោម តាមបុព្វសិទ្ធិលើភាគលាភ ឬបុព្វសិទ្ធិផ្សេងទៀតដើម្បីចូលរួម នៅក្នុងប្រាក់ចំណេញមិនទាន់បែងចែក ។ ដើម្បីគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនធម្មតានិងបន្សាបៈ

(ក) ប្រាក់ចំណេញ ឬខាត ដែលបែងចែកទៅឲ្យអ្នកកាន់មូលធនធម្មតា

របស់អង្គភាពមេត្រូវបានកែសម្រួល (ប្រាក់ចំណេញត្រូវបានកាត់បន្ថយនិងខាតត្រូវបានបង្កើន) ដោយទឹកប្រាក់ភាគលាភដែលបានប្រកាស ចែកនៅក្នុងការិយបរិច្ឆេទសម្រាប់ថ្នាក់នីមួយៗនៃភាគហ៊ុន និងដោយទឹកប្រាក់ភាគលាភតាមកិច្ចសន្យា (ឬការប្រាក់នៅពេលចូលរួមបំណ្ណបំណុល ) ដែលត្រូវបានបង់សម្រាប់ការិយបរិច្ឆេទ (ឧទាហរណ៍ ភាគលាភមិនបូកបន្ត) ។

(ខ) ប្រាក់ចំណេញឬខាតនៅសល់ត្រូវបានបែងចែកទៅជាភាគហ៊ុនធម្មតា និងឧបករណ៍មូលធន ដែលបានចូលរួម ចំពោះទំហំដែលភាគហ៊ុនឧបករណ៍នីមួយៗនៅក្នុងប្រាក់ចំណេញប្រសិនបើប្រាក់ចំណេញឬខាតទាំងអស់សម្រាប់ការិយបរិច្ឆេទត្រូវបានបែងចែក។ ប្រាក់ចំណេញ ឬ ខាតសរុប ដែលបានបែងចែកទៅក្នុងថ្នាក់នីមួយៗ នៃឧបករណ៍មូលធនត្រូវបានកំណត់ ដោយការបន្ថែមជាមួយនឹងទឹកប្រាក់ ដែលបែងចែកសម្រាប់ភាគលាភ និងទឹកប្រាក់ដែលបានបែងចែក សម្រាប់លក្ខណៈពិសេសក្នុងការចូលរួម។

(គ) ទឹកប្រាក់សរុបនៃប្រាក់ចំណេញ ឬខាត ដែលបានចែកចំពោះថ្នាក់នីមួយៗ នៃឧបករណ៍មូលធន ត្រូវបានចែកដោយចំនួនឧបករណ៍ដែលកំពុងដំណើរការចំពោះប្រាក់ចំណេញ ដែលត្រូវបានបែងចែកដើម្បីកំណត់ប្រាក់ចំណេញក្នុងភាគហ៊ុនសម្រាប់ឧបករណ៍នោះ ។ សម្រាប់ការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ស៊ាបភាគហ៊ុនធម្មតា ដែលមានសក្តានុពលទាំងអស់ ដែលបានសន្មតត្រូវបានរួមបញ្ចូលនៅក្នុង ភាគហ៊ុនធម្មតា ដែលកំពុងដំណើរការ ។

## ភាគហ៊ុនបង់រួចដោយផ្នែក

ក១៥ ពេលណាដែលភាគហ៊ុនត្រូវបានបោះផ្សាយ ប៉ុន្តែមិនត្រូវបានបង់ទាំងអស់ទេ ភាគហ៊ុនត្រូវបានទទួលស្គាល់ នៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន ជាប្រភាគនៃភាគហ៊ុនធម្មតា តាមទំហំដែលភាគហ៊ុនត្រូវបានផ្តល់សិទ្ធិឱ្យចូលនៅក្នុងភាគលាភក្នុងកំឡុងការិយបរិច្ឆេទ ដែលទាក់ទិននឹងភាគហ៊ុនធម្មតា ដែលបានបង់ពេញលេញ។

ក១៦ តាមទំហំដែលភាគហ៊ុនដែលបានបង់រួចមិនត្រូវបានផ្តល់សិទ្ធិ ដើម្បីចូលរួមនៅក្នុងភាគលាភក្នុងកំឡុងការិយបរិច្ឆេទ ដែលភាគហ៊ុនត្រូវបានទទួលស្គាល់ជាសមមូលនៃដីកា ឬសិទ្ធិពិសេស នៅក្នុងការគណនាប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាប។ សមតុល្យដែលមិនទាន់បង់ ត្រូវបានសន្មតថាតំណាងឱ្យចំណូលដែលបានប្រើ ដើម្បីទិញភាគហ៊ុនធម្មតា។ ចំនួននៃភាគហ៊ុន ដែលបានបញ្ចូលនៅក្នុងប្រាក់ចំណេញក្នុងមួយភាគហ៊ុនបន្ទាបគឺជាភាពខុសគ្នារវាងចំនួនភាគហ៊ុនដែលបានជាវ និងចំនួនភាគដែលបានសន្មតថានឹងត្រូវទិញ។

**ក្រុមប្រឹក្សាជាតិគណនេយ្យ**
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាស័យដ្ឋានៈ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែលៈ info@naccambodia.gov.kh | គេហទំព័រៈ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ